# សៀវភៅមគ្គុទេសក៍ស្ដីពីការស្ដារឡើងវិញពីគ្រោះមហន្តរាយ

## សម្រាប់វិស័យផ្លូវថ្នល់នៅកម្ពុជា

**TRANSPORT**



# ព័ត៌មានលម្អិតស្ដីពីរបាយការណ៍

| | | |
|---|---|---|
| **ចំណងជើងរបាយការណ៍** | ៖ | សៀវភៅមគ្គុទេសក៍ស្ដីពីការស្ដារឡើងវិញពីគ្រោះមហន្តរាយ |
| **គម្រោង** | ៖ | "គម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងគ្រោះមហន្តរាយ តាមរយៈការបង្កើនចំណេះដឹង" របស់ UNDP-ADB |
| **កិច្ចការរបស់អ្នករៀបរាង** | ៖ | ដឹកនាំ និងសម្របសម្រួលការកែសម្រួលវិធីសាស្ត្រ PDNA សម្រាប់ការអនុវត្តក្នុងវិស័យដឹកជញ្ជូន និងផ្លូវថ្នល់នៅកម្ពុជា និងការបង្កើតគោលការណ៍ណែនាំស្ដីពីការស្ដារវិស័យផ្លូវថ្នល់ឡើងវិញ |
| **ប្រទេស** | ៖ | កម្ពុជា |
| **កាលបរិច្ឆេទរបាយការណ៍** | ៖ | ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០២៣ |
| **ស្ថានភាពរបាយការណ៍** | ៖ | សម្រេច |
| **របាយការណ៍ត្រូវបានដាក់ជូន** | ៖ | លោកស្រី Rita Missal UNDP<br>លោកស្រី Joana Sampainho UNDP<br>លោក ឈុំ សុវណ្ណនី UNDP<br>លោក សំ សុផល UNDP |
| **របាយការណ៍ត្រូវបានរៀបចំឡើងដោយ** | ៖ | បណ្ឌិត Prerna Singh អ្នកឯកទេសផ្នែកវិស័យដឹកជញ្ជូន-អ្នកប្រឹក្សា UNDP |

# សេចក្តីថ្លែងអំណរគុណ

“សៀវភៅមគ្គុទេសក៍ស្តីពីការស្តារឡើងវិញពីគ្រោះមហន្តសម្រាប់វិស័យផ្លូវថ្នល់នៅកម្ពុជា” ត្រូវបានរៀបរៀងឡើងក្រោមគម្រោងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រោមគម្រោង ការកសាងហេដ្ឋារចនា សម្ព័ន្ធធន់នឹងគ្រោះមហន្តរាយតាមរយៈចំណេះដឹងដែលបានពង្រឹង។ ហិរញ្ញប្បទានឥតសំណងសម្រាប់គម្រោងនេះបានមកពីមូលនិធិជប៉ុនសម្រាប់វិបុលភាពនិងភាពធន់នៅអាស៊ីនិងប៉ាស៊ីហ្វិក (JFPR) ដែលផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលជប៉ុនតាមរយៈ ADB ។

គម្រោងជំនួយបច្ចេកទេសនេះ ត្រូវបានអនុវត្តដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) សហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ។ សៀវភៅមគ្គុទេសក៍នេះ កើតចេញពីកិច្ចសហការ ក៏ដូចជាការគាំទ្រ និងការផ្តល់ធាតុចូលជាបន្តបន្ទាប់ពីសំណាក់ដៃគូនានា ដូចជា ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) និងក្រសួងធនធានទឹក និងឧតុនិយម (MoWRAM)។ សៀវភៅមគ្គុទេសក៍នេះត្រូវបានរៀបរៀងឡើងក្រោមភាពជាដៃគូរវាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដើម្បីអនុវត្តលទ្ធផលរំពឹងទុកទី ៣ (ការបង្កើនសមត្ថភាពស្តារឡើងវិញដែលមានភាពធន់) នៃកម្មវិធីចំណេះដឹង និងជំនួយបច្ចេកទេសគាំទ្រ (KTSA) ស្តីពីការកសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងគ្រោះមហន្តរាយតាមរយៈការបង្កើនចំណេះដឹង។ គម្រោងរបស់ UNDP-ADB មានគោលបំណងបង្កើនសមត្ថភាពបច្ចេកទេសសម្រាប់ការរៀបចំផែនការស្តារឡើងវិញ និងការអនុវត្ត ដូចជា ការកែសម្រួលគោលការណ៍ណែនាំស្តីពីការវាយតម្លៃតម្រូវការក្រោយពេលមានគ្រោះមហន្តរាយ (PDNA) ឱ្យស្របទៅនឹងបរិបទជាតិ និងវិស័យហេដ្ឋារចនាសម្ព័ន្ធជាក់លាក់ និងការរៀបចំសេចក្តីណែនាំផ្អែកតាមបរិបទសម្រាប់ការស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ ដោយផ្តោតសំខាន់លើវិស័យផ្លូវថ្នល់នៅកម្ពុជា។

សៀវភៅមគ្គុទេសក៍នេះត្រូវបានរៀបរៀងឡើងដោយទីប្រឹក្សាឯករាជ្យ បណ្ឌិត Prerna Singh ក្រោមការត្រួតពិនិត្យជារួម និងការណែនាំផ្នែកបច្ចេកទេសដោយលោកស្រី Rita Missal ទីប្រឹក្សាផ្នែកការស្តារឡើងវិញនៃ UNDP លោកស្រី Joana Sampainho អ្នកវិភាគផ្នែកការស្តារឡើងវិញនៃ UNDP លោក ឈុំ សុវណ្ណនី អ្នកវិភាគកម្មវិធី UNDP ប្រចាំនៅកម្ពុជា និងក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយលោក សំ សុផល អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិនៅកម្ពុជា។

តាងនាមឱ្យភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមអភិវឌ្ឍសៀវភៅមគ្គុទេសក៍នេះ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ADB និង UNDP ដែលបានផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស តាមរយៈការដាក់បញ្ចូលការអភិវឌ្ឍសៀវភៅមគ្គុទេសក៍នេះទៅក្នុងគម្រោងបង្កើនសមត្ថភាពស្តារឡើងវិញដែលមានភាពធន់។ ក្រោមការដឹកនាំរបស់ ADB និង UNDP ទើបយើងអាចរៀបរៀងសៀវភៅមគ្គុទេសក៍នេះដោយជោគជ័យសម្រាប់ជាឯកសារជំនួយស្មារតីដល់មន្ត្រីរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធផ្សេងទៀត។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា និងមន្ត្រីមកពីក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានចំណាយពេលផ្តល់មតិយោបល់ដ៏មានតម្លៃចេញពីចំណេះដឹង និងបទពិសោធន៍យ៉ាងទូលំទូលាយរបស់ពួកគេ។ យើងខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកដែលបានបំពេញការងារកន្លងមក ដូចជា PDNA ពីមុន ផែនការស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ ការបណ្តុះបណ្តាល និងគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍវិស័យផ្លូវថ្នល់។

# មាតិកា

សេចក្តីថ្លែងអំណរគុណ ........ 3
មាតិកា ........ 5
ពាក្យកាត់ និងអក្សរកាត់ ........ 6
សេចក្តីផ្តើម ........ 8
បរិបទ ........ 8
វចនាសម្ព័ន្ធនៃសៀវភៅមគ្គុទេសក៍នេះ ........ 9
ការរៀបចំផែនការស្តារឡើងវិញមុនពេលមានគ្រោះមហន្តរាយ ........ 10
ពីការវាយតម្លៃតម្រូវការក្រោយពេលមានគ្រោះមហន្តរាយ ( PDNA ) ឆ្ពោះទៅរកការបន្តអនុវត្តក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ ( DRF ) ........ 11
គោលនយោបាយស្តីពីការស្តារវិស័យផ្លូវថ្នល់ឡើងវិញ ........ 12
ចក្ខុវិស័យស្នូលនៃការស្តារឡើងវិញ ........ 13
គោលការណ៍ណែនាំសម្រាប់ការស្តារឡើងវិញ ........ 15
កម្មវិធីស្តារវិស័យផ្លូវថ្នល់ឡើងវិញ ........ 16
ការរៀបចំផែនការប្រើប្រាស់ដីធ្លី ........ 20
ការរៀបចំផ្នែកស្ថាប័នសម្រាប់ការស្តារវិស័យផ្លូវថ្នល់ឡើងវិញ ........ 20
កំណត់បញ្ញត្តិ និងបញ្ជាក់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវ និងបង្កើតក្របខ័ណ្ឌប្រតិបត្តិ ........ 23
កំណត់បង្គោលចរ សម្រាប់ការប្រែក្លាយពីការស្តារឡើងវិញពីគ្រោះមហន្តរាយ ទៅជាការអភិវឌ្ឍក្រោយពេលមានគ្រោះមហន្តរាយ ........ 24
យន្តការផ្តល់ហិរញ្ញប្បទានដល់វិស័យផ្លូវថ្នល់ ........ 25
ការសម្របសម្រួល និងការគ្រប់គ្រងមូលនិធិដែលបានបែងចែក ........ 26
នីតិវិធីសម្រាប់ការអនុវត្តការស្តារវិស័យផ្លូវថ្នល់ឡើងវិញ ........ 28
បង្កើតស្តង់ដារនៃការស្ថាបនាឡើងវិញ ........ 28
កែសម្រួលយុទ្ធសាស្ត្រអនុវត្តន៍ដែលមានស្រាប់ឱ្យស្របទៅនឹងបរិបទនៃការស្តារឡើងវិញ ........ 32
បង្កើតប្រព័ន្ធបណ្តោះអាសន្ន និងកំណត់អាទិភាពគម្រោងភ្លាមៗ ........ 32
បង្កើតប្រព័ន្ធលទ្ធកម្មដែលត្រូវបានកែសម្រួលទៅតាមបរិបទនៃការស្តារឡើងវិញ ........ 33
ធានាការសម្របសម្រួលរដ្ឋាភិបាល និងគាំទ្រការអនុវត្តក្នុងមូលដ្ឋាន ........ 33
ធានាការចូលរួមរបស់សហគមន៍ ........ 35
បង្កើតប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ........ 36
បង្កើតយុទ្ធសាស្ត្រទំនាក់ទំនង ........ 40
ការរៀនសូត្រយ៉ាងសកម្ម ........ 43
គន្ថនិទ្ទេស ........ 43

# ពាក្យកាត់ និងអក្សរកាត់

| | |
|---|---|
| **ADB** | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **BBB** | ការកសាងឡើងវិញឱ្យកាន់តែប្រសើរ |
| **CamDi** | ប្រព័ន្ធគ្រប់គ្រងទិន្នន័យការបាត់បង់ និងការខូចខាតដោយគ្រោះមហន្តរាយនៅកម្ពុជា (Camdi) |
| **CCDM** | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ |
| **DCDM** | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក |
| **DRF** | ក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ |
| **DRR** | ការឆ្លើយតប និងស្តារឡើងវិញពីគ្រោះមហន្តរាយ |
| **EU** | សហភាពអឺរ៉ុប |
| **FASMEC** | សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា |
| **FHWA** | រដ្ឋបាលផ្លូវហាយវេសហព័ន្ធ |
| **GFDRR** | កម្មវិធីសកលសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ និងការស្តារឡើងវិញ |
| **GRADE** | ការប៉ាន់ស្មានរហ័សជាសកលលើការខូចខាតក្រោយពេលមានគ្រោះមហន្តរាយ |
| **GRM** | យន្តការដោះស្រាយបណ្តឹង |
| **HRF** | វេទិកាឆ្លើយតបផ្នែកមនុស្សធម៌ |
| **IFI** | គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ |
| **IRI** | សន្ទស្សន៍អន្តរជាតិនៃភាពមិនរាបស្មើ (ផ្លូវថ្នល់) |
| **JAG** | ក្រុមធ្វើសកម្មភាពរួម |
| **LDC** | ប្រទេសមានការអភិវឌ្ឍន៍តិចតួច |

| | |
|---|---|
| **M&E** | ការពិនិត្យតាមដាន និងវាយតម្លៃ |
| **MEF** | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MIS** | ប្រព័ន្ធគ្រប់គ្រងព័ត៌មាន |
| **MoE** | ក្រសួងបរិស្ថាន |
| **MoWRAM** | ក្រសួងធនធានទឹក និងឧតុនិយម |
| **MPWT** | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **MRD** | ក្រសួងអភិវឌ្ឍន៍ជនបទ |
| **NCDM** | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **O&M** | ប្រតិបត្តិការ និងការថែទាំ |
| **PADEK** | អង្គការភាពជាដៃគូដើម្បីការអភិវឌ្ឍនៅកម្ពុជា |
| **PCDM** | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត |
| **PDNA** | ការវាយតម្លៃតម្រូវការក្រោយពេលមានគ្រោះមហន្តរាយ |
| **PSR** | ការវាយតម្លៃកម្រិតលទ្ធភាពផ្តល់សេវានាពេលបច្ចុប្បន្ន |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **UNDG** | ក្រុមអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ |
| **WB** | ធនាគារពិភពលោក |

# សេចក្តីផ្តើម

ស្ថានភាពក្រោយពេលមានគ្រោះមហន្តរាយ ពោរពេញដោយភាពស្មុគស្មាញ និងការខ្វះខាត ដែលទាមទារការឆ្លើយតបរហ័ស សម្រាប់ការវាយតម្លៃតម្រូវការភ្លាមៗ និងការផ្តល់ជំនួយដើម្បីសង្គ្រោះអាយុជីវិត ទន្ទឹមនឹងការវាយតម្លៃការខូចខាត និងការបាត់បង់ និងការរៀបចំផែនការស្តារឡើងវិញប្រកបដោយប្រសិទ្ធភាព ដើម្បីធានាដំណើរការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដោយមានការពិចារណាល្អិតល្អន់លើការកាត់បន្ថយហានិភ័យក្នុងពេលមានគ្រោះមហន្តរាយ។

ដំណាក់កាលស្តារឡើងវិញក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយ រំលេចការផ្លាស់ប្តូរពីជំនួយសង្គ្រោះបន្ទាន់ភ្លាមៗទៅជាការស្តារប្រព័ន្ធនានា តាមរបៀបដែលរក្សាតុល្យភាពនៃតម្រូវការរយៈពេលខ្លី ក៏ដូចជាបង្កើតប្រព័ន្ធកាន់តែប្រសើរមួយដើម្បីកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់អវិជ្ជមានដោយសារការរាំងស្ទះ ដែលអាចកើតឡើងនាពេលអនាគត។ ចំណុចនេះលេចចេញពីតម្រូវការស្តារឡើងវិញដែលបានកំណត់ក្នុងដំណើរការវាយតម្លៃតម្រូវការក្រោយពេលមានគ្រោះមហន្តរាយ (PDNA) និងឈានទៅរកការបង្កើតក្របខ័ណ្ឌស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ (DRF)។

ក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ ជួយឱ្យប្រទេសមួយទទួលបានដំណើរការស្តារឡើងវិញដែលកៀរគរភាគីពាក់ព័ន្ធទាំងអស់ ដូចជា រដ្ឋាភិបាល វិស័យឯកជន ម្ចាស់ជំនួយ ដៃគូអភិវឌ្ឍន៍ និងសហគមន៍ ដើម្បីស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ ដោយផ្តោតសំខាន់លើការកសាងឡើងវិញឱ្យកាន់តែប្រសើរ កាន់តែរឹងមាំ និងកាន់តែមានបរិយាប័ន្នក្នុងរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង (GFDRR, 2020)។ ជាទូទៅ ក្របខ័ណ្ឌនេះត្រូវបានបង្កើតឡើងក្រោយពេលមានគ្រោះមហន្តរាយ ដោយដាក់បញ្ចូលផលប៉ះពាល់តាមបរិបទនៃគ្រោះមហន្តរាយទៅក្នុងយុទ្ធសាស្ត្រស្តារឡើងវិញ ក្នុងរយៈពេល ៤-៨ សប្តាហ៍ក្រោយពេលមានគ្រោះមហន្តរាយ។

សៀវភៅមគ្គុទេសក៍នេះច្របាច់បញ្ចូលគ្នានូវដំណើរការ ដែលមានរៀបរាប់ក្នុងសៀវភៅមគ្គុទេសក៍ក្របខ័ណ្ឌស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយរបស់ GFDRR (GFDRR, 2020) ដោយច្បាមយកចំណេះដឹងពីឯកសារស្រាវជ្រាវដែលពាក់ព័ន្ធនឹងការឆ្លើយតបនឹងគ្រោះមហន្តរាយ ការស្តារឡើងវិញ និងការរៀបចំផែនការបង្កើនភាពធន់។ សៀវភៅមគ្គុទេសក៍នេះផ្តល់ការណែនាំផ្អែកតាមបរិបទសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយ ដែលគ្របដណ្តប់លើចំណុចចាំបាច់សម្រាប់ការស្តារឡើងវិញប្រកបដោយប្រសិទ្ធភាព កាន់តែប្រសើរ និងប្រកបដោយសមធម៌ក្រោយពេលមានគ្រោះមហន្តរាយ ជាពិសេសសម្រាប់វិស័យផ្លូវថ្នល់នៅកម្ពុជា។

## បរិបទ

សន្ទស្សន៍សម្រាប់ការគ្រប់គ្រងហានិភ័យ (INFORM) និងសន្ទស្សន៍ហានិភ័យសកល (GRI) សម្រាប់កម្ពុជាបង្ហាញពីកម្រងព័ត៌មានហានិភ័យរបស់កម្ពុជា។ គ្រោះទឹកជំនន់ត្រូវបានកំណត់ជាមុខសញ្ញាគ្រោះថ្នាក់ ដែលមានពិន្ទុប្រឈមខ្ពស់ជាងគេនៅកម្ពុជា (៩,៥/១០) ដោយបង្កផលប៉ះពាល់លើផ្ទៃដីជិត ៧៥% នៃទំនាបលិចទឹកបឹងទន្លេសាប។ ព្យុះទីហ្វុង និងព្យុះកំបុតត្បូងដែលជាមុខសញ្ញាគ្រោះថ្នាក់ទីពីរដែលមានពិន្ទុប្រឈមខ្ពស់ជាងគេ ក៏បង្កផលវិបាកធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ចសង្គមរបស់កម្ពុជាផងដែរ។

ការលេចឡើងជាបន្តបន្ទាប់នៃមុខសញ្ញាគ្រោះថ្នាក់នានា បូករួមនឹងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចសង្គមនៅកម្ពុជា បានបង្កើនផលប៉ះពាល់អវិជ្ជមានដោយសារព្រឹត្តិការណ៍រាំងស្ទះទាំងនេះ។ ការខូចខាតដែលពាក់ព័ន្ធនឹងគ្រោះទឹកជំនន់ខែ តុលា ឆ្នាំ ២០១៣ តែមួយមុខ ដែលបង្កឡើងដោយការធ្លាក់ភ្លៀងខ្លាំង និងការរីកមាឌទន្លេមេគង្គនៅរដូវវស្សា ត្រូវបានប៉ាន់ស្មានមានតម្លៃ ៣៥៦ លានដុល្លារ និងធ្វើឱ្យប៉ះពាល់ដល់ខេត្តចំនួន ២០ ក្នុងចំណោមខេត្តទាំង ២៤ និងប្រជាជនចំនួន ១,៧ លាននាក់។

វិស័យផ្លូវថ្នល់ ដែលជាចំណុចផ្តោតសំខាន់នៃសៀវភៅមគ្គុទេសក៍នេះ ជាអនុវិស័យធំជាងគេនៅកម្ពុជា ដែលមានប្រវែងសរុបជាង ៦១.០០០ គីឡូម៉ែត្រ។ នៅកម្ពុជា ផ្លូវថ្នល់ចំនួន ៦៥% គឺសម្រាប់ការដឹកជញ្ជូនទំនិញ និងចំនួន ៨៧% គឺសម្រាប់អ្នកដំណើរ។ ផ្លូវថ្នល់ក៏ជាប្រព័ន្ធមួយដែលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុតដោយសារទឹកជំនន់ និងព្យុះទីហ្វុងផងដែរ។ ទិន្នន័យពីប្រព័ន្ធគ្រប់គ្រងទិន្នន័យការបាត់បង់ និងការខូចខាតដោយគ្រោះមហន្តរាយនៅកម្ពុជា (Camdi) បង្ហាញថា ចាប់ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១៤ ផ្លូវថ្នល់សរុបប្រវែង ១០.១៩១ គីឡូម៉ែត្រ ត្រូវបានជន់លិចដោយទឹកជំនន់ ឬទឹកភ្លៀង ក្នុងនោះ ផ្លូវថ្នល់ ៤៧% រងការខូចខាត និង ២១% រងការបំផ្លិចបំផ្លាញ។

គ្រោះមហន្តរាយខ្យល់ព្យុះកេតសាណាឆ្នាំ ២០០៩ បានបង្កការខូចខាតដល់បណ្តាញផ្លូវថ្នល់ក្នុងខេត្តចំនួន ១៨ នៅកម្ពុជា ជាមួយនឹងការបាត់បង់ដែលមានតម្លៃ ១១,០៧ លានដុល្លារ (ចំណាយខ្ពស់លើប្រតិបត្តិការយានជំនិះ និងរយៈពេលយូរក្នុងដឹកជញ្ជូនទំនិញ និងធ្វើដំណើរ ដែលបណ្តាលមកពីស្ថានភាពផ្លូវថ្នល់មិនល្អ)។ ក្នុងឆ្នាំ ២០១១ ទឹកជំនន់បានបង្កផលប៉ះពាល់លើ ១៨ ខេត្តក្នុងចំណោម ២៤ ខេត្តនៅកម្ពុជា ហើយបើធៀបនឹងផលប៉ះពាល់ដោយសារខ្យល់ព្យុះ Ketsana ក្នុងឆ្នាំ ២០០៩ ការខូចខាតលើកនេះត្រូវបានប៉ាន់ស្មានថាច្រើនជាងរហូតដល់ ៨ ដង (៣២៨,៦ លានដុល្លារ) ចំណែកការបាត់បង់ត្រូវបានប៉ាន់ស្មានថាច្រើនជាងរហូតដល់ ២ ដង (២៣,៣ លានដុល្លារ)។

ទោះបីជាការរាំងស្ទះនេះ មិនធ្វើឱ្យខូចខាតរចនាសម្ព័ន្ធផ្លូវថ្នល់ក៏ដោយ ប៉ុន្តែទឹកជំនន់ និងព្យុះទីហ្វុងបានបង្អាក់មុខងាររបស់ផ្លូវថ្នល់ក្នុងពេលមានគ្រោះមហន្តរាយ។ ដូច្នេះ គ្រោះមហន្តរាយទាំងនេះបានរឹតត្បិតបំលាស់ទីទំនិញ និងមនុស្សសម្រាប់សកម្មភាពសំខាន់ៗ ដូចជា ការជម្លៀស ការផ្គត់ផ្គង់សម្ភារវេជ្ជសាស្ត្រ ការផ្គត់ផ្គង់ស្បៀងអាហារ និងទឹក ការអប់រំ និងសកម្មភាពសេដ្ឋកិច្ចសង្គមទូទៅប្រចាំថ្ងៃ។ ការឆ្លើយតបភ្លាមៗមានសារៈសំខាន់ណាស់ក្នុងការស្តារកំណាត់ផ្លូវដែលសម្រួលដល់ការដំណើរការសេវាសង្គ្រោះបន្ទាន់។ ទោះជាយ៉ាងណា ការរៀបចំផែនការស្តារកំណាត់ផ្លូវឡើងវិញក្នុងរយៈពេលវែង ជាកត្តាចាំបាច់ក្នុងការសម្រួលដល់ការស្តារសហគមន៍ និងការស្តារសេដ្ឋកិច្ចឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ។

## រចនាសម្ព័ន្ធនៃសៀវភៅមគ្គុទេសក៍នេះ

សៀវភៅមគ្គុទេសក៍ស្តីពីការស្តារឡើងវិញពីគ្រោះមហន្តរាយផ្តល់វិធីសាស្ត្រដែលផ្អែកតាមការអនុវត្ត និងផ្តោតលើលទ្ធផលដល់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូសម្រាប់ការស្តារវិស័យផ្លូវថ្នល់ឱ្យមានភាពធន់ឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ។ សៀវភៅមគ្គុទេសក៍នេះបង្ហាញពីក្របខ័ណ្ឌទូទៅនៃការស្តារឡើងវិញពីគ្រោះមហន្តរាយសម្រាប់ការស្តារវិស័យផ្លូវថ្នល់ឡើងវិញ និងផ្តល់ការណែនាំពីការកែសម្រួលសមស្របដែលចាំបាច់សម្រាប់ការបង្កើតក្របខ័ណ្ឌស្តារវិស័យផ្លូវថ្នល់ឡើងវិញ ក្រោយពេលមានគ្រោះមហន្តរាយធ្ងន់ធ្ងរណាមួយ។ សៀវភៅមគ្គុទេសក៍នេះចែកជា ៤ ម៉ូឌុល ដែលត្រូវបានកំណត់បរិបទសម្រាប់វិស័យផ្លូវថ្នល់នៅកម្ពុជា ៖

- ការរៀបចំផែនការស្តារឡើងវិញមុនពេលមានគ្រោះមហន្តរាយ
- ពី PDNA ឆ្ពោះទៅរកការបន្តអនុវត្ត DRF
- គោលនយោបាយស្តារឡើងវិញ
- ការរៀបចំផ្នែកស្ថាប័នសម្រាប់ការស្តារឡើងវិញ
- យន្តការផ្តល់ហិរញ្ញប្បទាន
- នីតិវិធីសម្រាប់ការអនុវត្តការស្តារឡើងវិញ

មេរៀនពី PDNAs កន្លងមក និងការគ្រប់គ្រងគ្រោះមហន្តរាយវិស័យផ្លូវថ្នល់នៅកម្ពុជា ត្រូវបានដាក់បញ្ចូលក្នុងឯកសារនេះ ដើម្បីផ្តល់ជាអនុសាសន៍ដល់មន្ត្រីកម្ពុជាក្នុងពេលអភិវឌ្ឍក្របខ័ណ្ឌស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ។

## ការរៀបចំផែនការស្តារឡើងវិញមុនពេលមានគ្រោះមហន្តរាយ

ដើម្បីអនុវត្តដោយជោគជ័យនូវផ្នែកនីមួយៗនៃក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ ក្នុងដំណាក់កាលស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ ចាំបាច់ត្រូវរៀបចំផែនការមុនពេលមានមានគ្រោះមហន្តរាយ។ ការប៉ាន់ស្មាន និងការត្រៀមខ្លួនមុនពេលមានគ្រោះមហន្តរាយ អាចជួយជំរុញការឆ្លើយតបនឹងគ្រោះមហន្តរាយឱ្យបានកាន់តែឆាប់រហ័ស កាន់តែរលូន និងកាន់តែមានបរិយាបន្ន។ ចំណុចនេះរួមបញ្ចូលការពង្រឹងប្រព័ន្ធសំខាន់ៗក្នុងដំណាក់កាលមុនពេលមានគ្រោះមហន្តរាយ និងការកំណត់ការរៀបចំដែលអាចកាត់បន្ថយការចំណាយពេលយូរក្នុងសកម្មភាពស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ។ ប្រព័ន្ធសំខាន់ៗសម្រាប់ការស្តារកំណាត់ផ្លូវឡើងវិញពីគ្រោះមហន្តរាយ រួមមាន ៖

១ ការរៀបចំផ្នែកស្ថាប័នសម្រាប់ការគ្រប់គ្រងវិស័យផ្លូវថ្នល់ដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ

២ ភាគីពាក់ព័ន្ធក្នុងដំណើរការស្តារឡើងវិញ ជាពិសេសគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងឃុំ

៣ ប្រព័ន្ធហិរញ្ញវត្ថុដែលត្រូវបានបង្កើតឡើងសម្រាប់គ្រប់គ្រងការអភិវឌ្ឍ និងការស្តារផ្លូវថ្នល់ឡើងវិញ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ធាតុផ្សំសំខាន់ៗ ៣ សម្រាប់ការរៀបចំផែនការមុនពេលមានគ្រោះមហន្តរាយ ដែលអាចគេអាចប្រើប្រាស់សម្រាប់ពង្រឹងប្រព័ន្ធស្តារឡើងវិញមុនពេលគ្រោះមហន្តរាយ រួមមាន ៖

- ការវិភាគសមិទ្ធកម្មប្រព័ន្ធ និងហានិភ័យ
- ក្របខ័ណ្ឌស្តារឡើងវិញទូទៅ
- ផែនការត្រៀមរៀបចំហិរញ្ញវត្ថុ

ការវិភាគស្ថានភាព និងសមិទ្ធកម្មប្រព័ន្ធផ្លូវថ្នល់មុនពេលមានគ្រោះមហន្តរាយ អាចជាមូលដ្ឋានសម្រាប់វាស់វែងការខូចខាត និងការបាត់បង់ដោយសារគ្រោះមហន្តរាយ ហើយការវិភាគភាពងាយរងគ្រោះអាចផ្តល់មូលដ្ឋានព័ត៌មានដល់តម្រូវការស្តារឡើងវិញ។ ការវិភាគទាំងពីរនេះសុទ្ធតែជាផ្នែកសំខាន់ៗនៃដំណើរការ PDNA។ ក្របខ័ណ្ឌស្តារឡើងវិញទូទៅ ដែលត្រូវបានបង្កើតឡើងមុនពេលមានគ្រោះមហន្តរាយ (មានបង្ហាញក្នុងសៀវភៅមគ្គុទេសក៍នេះ) រួមបញ្ចូលជាស្រេចនូវការគិតគូរពីបរិបទនៃវិស័យផ្លូវថ្នល់ និងបរិបទរបស់កម្ពុជា និងទាមទារតែការកែសម្រួលឡើងវិញទៅតាមតម្រូវការដែលបានកំណត់ និងគ្រោះមហន្តរាយជាក់លាក់តែប៉ុណ្ណោះ។ ក្របខ័ណ្ឌទូទៅនេះអាចជាចំណុចចាប់ផ្តើមមួយដែលបន្សុីគ្នានឹងគោលដៅអភិវឌ្ឍន៍វិស័យផ្លូវថ្នល់នៅកម្ពុជា ដោយតម្រឹមតម្រង់ក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយឱ្យស្ថិតក្នុងទិសដៅត្រឹមត្រូវ ដើម្បីសម្រាលកិច្ចខិតខំប្រឹងប្រែងក្រោយពេលមានគ្រោះមហន្តរាយ។ ក្រៅពីនេះ ផែនការត្រៀមរៀបចំហិរញ្ញវត្ថុនឹងគាំទ្រដល់ការអនុវត្តយ៉ាងឆាប់រហ័សនូវក្របខ័ណ្ឌស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ។

សៀវភៅមគ្គុទេសក៍នេះផ្តល់មូលដ្ឋានសម្រាប់ធាតុផ្សំទាំង ៣ ក្នុងការរៀបចំផែនការមុនពេលមានគ្រោះមហន្តរាយ នៅក្នុងផ្នែកនីមួយៗ និងគូសបញ្ជាក់ពីធាតុផ្សំដែលមានស្រាប់ក្នុងការត្រៀមខ្លួនរបស់កម្ពុជា នៅក្នុងធាតុផ្សំនីមួយៗនៃក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ និងរបៀបដែលធាតុផ្សំទាំងនោះមានទំនាក់ទំនងទៅនឹងសកម្មភាពដែលត្រូវធ្វើឡើងក្រោយពេលមានគ្រោះមហន្តរាយ។

# ពីការវាយតម្លៃតម្រូវការក្រោយពេលមានគ្រោះមហន្តរាយ (PDNA) ឆ្ពោះទៅរកការបន្តអនុវត្តក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ (DRF)

ការវាយតម្លៃតម្រូវការក្រោយពេលមានគ្រោះមហន្តរាយ (PDNA) ជាបុរេលក្ខខណ្ឌមួយសម្រាប់ការអភិវឌ្ឍក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ។ ការវាយតម្លៃនេះជាវិធីសាស្ត្រមួយដែលបង្កើតឡើងរួមគ្នាដោយសហភាពអឺរ៉ុប អង្គការសហប្រជាជាតិ និងធនាគារពិភពលោកដើម្បីជួយដល់រដ្ឋាភិបាលក្នុងការវាយតម្លៃការខូចខាតការបាត់បង់ និងតម្រូវការស្តារឡើងវិញ។ នៅថ្នាក់ជាតិ ការវាយតម្លៃនេះជាលំហាត់ពហុវិស័យដែលដឹកនាំដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តនៅតាមបណ្តាខេត្តដែលរងផលប៉ះពាល់ ដែលសម្រួលដល់ការប្រែក្លាយពីជំនួយសង្គ្រោះទៅជាការអភិវឌ្ឍ។ ខណៈដែលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដឹកនាំដំណើរការ PDNA ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ផ្តល់ព័ត៌មានលម្អិតផ្អែកតាមបរិបទស្តីពីការខូចខាត និងការបាត់បង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ចំណែកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត គាំទ្រដល់ដំណើរការ PDNA នៅថ្នាក់ខេត្ត។ សេចក្តីណែនាំលម្អិតស្តីពីដំណើរការ PDNA ក្នុងវិស័យផ្លូវថ្នល់នៅកម្ពុជាត្រូវបានបង្កើតឡើងជាផ្នែកមួយនៃគម្រោងរបស់ UNDP-ADB (គម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងគ្រោះមហន្តរាយតាមរយៈការបង្កើនចំណេះដឹង) (Singh, PDNA Guidelines: Roadways Sector in Cambodia (Draft), 2022)។

ក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ យកលំនាំតាម PDNA និងបង្ហាញពី “របៀប” បំពេញតម្រូវការស្តារឡើងវិញ និងការអនុវត្តយុទ្ធសាស្ត្រស្តារឡើងវិញ។ PDNA ផ្តោតសំខាន់លើការវាយតម្លៃផលជះ ផលប៉ះពាល់ និងតម្រូវការ និងដាក់ចេញយុទ្ធសាស្ត្រស្តារឡើងវិញ។ ក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ ផ្តោតការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រស្តារឡើងវិញ (រូបភាពទី ១) និងរៀបរាប់លម្អិតពីវិធានការស្តារឡើងវិញ ជាមួយការផ្តោតសំខាន់លើការបង្កើតក្របខ័ណ្ឌសម្រាប់ការបញ្ជ្រាបយុទ្ធសាស្ត្រនោះទៅក្នុងស្ថាប័ន ការបង្កើតប្រព័ន្ធអនុវត្តន៍យុទ្ធសាស្ត្រនោះ និងការកំណត់យន្តការហិរញ្ញវត្ថុដើម្បីគាំទ្រដល់ដំណើរការនេះ។ ក្របខ័ណ្ឌនេះក៏រ៉ាយរ៉ាប់ពីសកម្មភាពស្តារឡើងវិញតាមលំដាប់លំដោយ ដោយផ្អែកតាមការកំណត់អាទិភាពហិរញ្ញប្បទានដែលមាន និងសមត្ថភាពរៀបចំការអនុវត្តរបស់វិស័យផ្លូវថ្នល់ និងសមត្ថភាពរបស់ប្រទេសកម្ពុជា តាមរយៈការតម្រឹមតម្រង់ទៅតាមតម្រូវការរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែងផងដែរ។




រូបភាពទី ១ ៖ ពី PDNA ឆ្ពោះទៅរក DRF (GFDRR, 2020)

ការសំខាន់គឺភាគីពាក់ព័ន្ធដែលចូលរួមក្នុងការអភិវឌ្ឍក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ ត្រូវគិតគូរពីភាពចាំបាច់នៃការបន្តអនុវត្តខាងលើ។ វិធីដ៏ល្អមួយសម្រាប់ធានាការបន្តអនុវត្តនេះ គឺត្រូវធានាលំហូរទិន្នន័យ និងព័ត៌មានស្តីពីគោលនយោបាយស្តារឡើងវិញ និងគោលបំណងនៃការពង្រឹងភាពធន់ និងនិរន្តរភាព សម្រាប់អ្នកដែលមានតួនាទីដឹកនាំការឆ្លើយតបភ្លាមៗក្រោយពេលមានគ្រោះមហន្តរាយ។ ដូច្នេះ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ចាំបាច់ត្រូវផ្ដោះប្ដូរព័ត៌មានជាមួយគ្នា ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ ស្ដីពីនិរន្តភាពវិស័យផ្លូវថ្នល់ និងគោលបំណងពង្រឹងភាពធន់ គោលបំណងជាតិស្តីពីការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងគោលបំណងរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយស្តីពីការឆ្លើយតបនឹងគ្រោះមហន្តរាយ។

# គោលនយោបាយស្តីពីការស្តារវិស័យផ្លូវថ្នល់ឡើងវិញ

គោលនយោបាយស្តារឡើងវិញដែលជាផ្នែកមួយនៃក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ ផ្តោតសំខាន់លើការបង្កើតសេចក្តីថ្លែងគោលបំណងសម្រាប់ជាត្រីវិស័យដល់ការសម្រេចចិត្តស្តារឡើងវិញ។ គោលនយោបាយស្តារឡើងវិញដែលពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់នេះ កំណត់ចំណុចដៅ និងបង្កើតគោលការណ៍សម្រាប់ការស្តារស្ថានភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ចល័តភាព និងភាពងាយស្រួលក្នុងការទទួលបានសេវាសម្រាប់សហគមន៍ ឱ្យដូចកម្រិតមុនពេលមានគ្រោះមហន្តរាយ ឬមានកម្រិតប្រសើរជាងមុន ដោយផ្អែកតាមវិធីសាស្រ្តនៃការកសាងឡើងវិញឱ្យកាន់តែប្រសើរ។

ធាតុផ្សំសំខាន់ៗនៃគោលនយោបាយស្តារឡើងវិញរួមមាន ៖

- ចក្ខុវិស័យស្នូលនៃការស្តារឡើងវិញ
- គោលការណ៍ណែនាំសម្រាប់ការស្តារឡើងវិញ
- ការកំណត់កម្មវិធីស្តារឡើងវិញ
- ការរៀបចំផែនការប្រើប្រាស់ដីធ្លី

គួរកត់សម្គាល់ផងដែរថា គោលនយោបាយវិស័យផ្លូវថ្នល់គួរបន្សីគ្នានឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ការដឹកជញ្ជូនដើរតួនាទីសំខាន់ក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១ និងទី ២ (មិនមានភាពក្រីក្រ និងផលិតភាពកសិកម្ម) តាមរយៈការផ្តល់បណ្តាញផ្លូវតភ្ជាប់ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៣ (សុខភាពល្អ និងសុខុមាលភាព) តាមរយៈការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ (ចំណុចដៅ ៣.៦) និងការបំពុល (ចំណុចដៅ ៣.៩) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៧ (ថាមពលស្អាត និងមានតម្លៃសមរម្យ) តាមរយៈការបង្កើនប្រសិទ្ធភាពថាមពលក្នុងការដឹកជញ្ជូន (ចំណុចដៅ ៧.៣) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៨ (កំណើនសេដ្ឋកិច្ច និងការងារពេញលេញ និងមានផលិតភាព) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៩ ( ឧស្សាហកម្ម នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ) តាមរយៈហេដ្ឋារចនាសម្ព័ន្ធដែលមាននិរន្តរភាពសម្រាប់ទាំងអស់គ្នា (ចំណុចដៅ ៩.១) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១១ (ទីក្រុង និងសហគមន៍ដែលមាននិរន្តរភាព) តាមរយៈប្រព័ន្ធដឹកជញ្ជូនសាធារណៈក្នុងទីក្រុងដែលមាននិរន្តរភាព (ចំណុចដៅ ១១.២) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១២ (ការផលិត និងការប្រើប្រាស់ដែលមានការទទួលខុសត្រូវ) តាមរយៈការកាត់បន្ថយ

ឧបត្ថម្ភធនឥន្ធនៈ (ចំណុចដៅ ១២.២) និងការកាត់បន្ថយការបាត់បង់ និងការខ្ជះខ្ជាយអាហារ (ចំណុចដៅ ១២.៣) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១៣ (សកម្មភាពអាកាសធាតុ) តាមរយៈការរួមចំណែកដល់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (ចំណុចដៅ ១៣.១) ការកាត់បន្ថយផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ (ចំណុចដៅ ១៣.២) និងមហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ (World Bank, 2016)។

គេអាចទាញប្រយោជន៍ពីការផ្សារភ្ជាប់គោលនយោបាយស្តារឡើងវិញ ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព តាមរយៈការដាក់សំណើសុំជំនួយមូលនិធិដែលផ្តោតសំខាន់លើការលើកកម្ពស់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

# ចក្ខុវិស័យស្នូលនៃការស្តារឡើងវិញ

ផ្អែកតាមការពិនិត្យឡើងវិញលើចក្ខុវិស័យកំណើនវិស័យផ្លូវថ្នល់នៅកម្ពុជា ចក្ខុវិស័យជាតិនៃការស្តារឡើងវិញរបស់កម្ពុជា និងយុទ្ធសាស្រ្តកំណើនជារួមរបស់កម្ពុជា នៅឆ្នាំ ២០២២ ចក្ខុវិស័យស្នូលនៃការស្តារវិស័យផ្លូវថ្នល់ឡើងវិញ ផ្តោតសំខាន់លើ ៖

"ការផ្តល់**សុវត្ថិភាព ចល័តភាព** និងភាព**ងាយស្រួល**ដល់សហគមន៍ ដោយផ្តោតសំខានលើការធានាសមាហរណកម្មសហគមន៍ជនបទទៅក្នុង**សេដ្ឋកិច្ចជាតិ** និង**ស្តារឡើងវិញ** និង**ការធ្វើទំនើបកម្មប្រកបដោយប្រសិទ្ធភាព**នូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងស្ថាប័នដើម្បីធានាភាពធន់"។

ចក្ខុវិស័យនៃការស្តារឡើងវិញនេះ កើតចេញពីការច្របាច់បញ្ចូលគ្នានូវយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរបស់កម្ពុជា ចក្ខុវិស័យនៃការស្តារឡើងវិញពីគ្រោះមហន្តរាយ (គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ) ចក្ខុវិស័យកំណើនវិស័យផ្លូវថ្នល់ (ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ) និងចក្ខុវិស័យកំណើនវិស័យផ្លូវថ្នល់សម្រាប់កម្ពុជា (ធនាគារអភិវឌ្ឍន៍អាស៊ី)។ ចក្ខុវិស័យទាំងនេះ មានបង្ហាញក្នុងប្រអប់ទី ១។

**ប្រអប់ទី ១ ៖ ចក្ខុវិស័យយុទ្ធសាស្រ្តរបស់កម្ពុជា ចក្ខុវិស័យស្តារឡើងវិញរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងចក្ខុវិស័យកំណើនវិស័យដឹកជញ្ជូននៅកម្ពុជា**

ចក្ខុវិស័យអភិវឌ្ឍន៍ជាតិរបស់កម្ពុជា យកលំនាំតាមយុទ្ធសាស្រ្តចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព (ADB, 2019)។ យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី ៤ ដែលត្រូវបានអនុវត្តក្នុងឆ្នាំ ២០១៨ ចាត់ទុកគោលបំណង ៤ ខាងក្រោមជាអាទិភាពស្នូល ៖

- ធានាកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧%
- បង្កើតការងារកាន់តែច្រើន
- សម្រេចបានចំណុចដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យនៅទាបជាង ១០%
- បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចស្ថាប័នសាធារណៈ

ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (NAP-DRR) ២០១៩-២០២៣ កំណត់ពីសកម្មភាពអាទិភាពក្នុងវិស័យចំនួន ៥ (CFE-DM, 2020) ៖

- ការយល់ពីហានិភ័យ
- ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ
- ការវិនិយោគ/ការផ្តល់ហិរញ្ញប្បទានដល់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR)
- ការបង្កើនការត្រៀមខ្លួន និងការកសាងឡើងវិញឱ្យកាន់តែប្រសើរ (BBB)
- ការធានាសង្គតិភាព និងបរិយាបន្ន

ចក្ខុវិស័យយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់វិស័យដឹកជញ្ជូនរបស់កម្ពុជា គឺការស្តារ ការស្ថាបនាឡើងវិញ និងការធ្វើទំនើបកម្មប្រព័ន្ធដឹកជញ្ជូនស្ទួលរបស់កម្ពុជា។ យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រដែលព្រាងឡើងដោយក្រសួងសាធារណការ និងដឹកជញ្ជូនសម្រាប់ការអភិវឌ្ឍវិស័យដឹកជញ្ជូន បានកំណត់គោលបំណងសំខាន់ ៥ ដូចខាងក្រោម ៖

- ប្រព័ន្ធដឹកជញ្ជូនដែលមានប្រសិទ្ធភាពចំណាយ ជាពិសេសសម្រាប់ភស្តុភារកម្ម ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចដែលមាននិរន្តរភាព និងការលើកកម្ពស់ពាណិជ្ជកម្មពីក្រៅប្រទេស និងការវិនិយោគផ្ទាល់ពីបរទេស
- សមាហរណកម្មតំបន់ជនបទទៅក្នុងសេដ្ឋកិច្ចជាតិ តាមរយៈការផ្សារភ្ជាប់តំបន់ជនបទទៅនឹងបណ្តាញផ្លូវដឹកជញ្ជូន ដើម្បីជំរុញសកម្មភាពដែលមានផលិតភាពនៅក្នុងតំបន់ដែលមិនត្រូវបានធ្វើសមាហរណកម្មកន្លងមក ដើម្បីទ្រទ្រង់ដល់ការកាត់បន្ថយភាពក្រីក្រ និងសមាហរណកម្មកម្ពុជា
- ការពង្រឹងស្ថាប័នវិស័យដឹកជញ្ជូន និងសមត្ថភាពរបស់ស្ថាប័នទាំងនោះតាមរយៈការជំរុញឱ្យវិស័យឯកជនចូលរួមក្នុងការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធ
- ការជំរុញការចូលរួមរបស់វិនិយោគិនបរទេស និងក្នុងស្រុក ក្នុងការផ្តល់ហិរញ្ញប្បទាន ការអភិវឌ្ឍ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន
- ការបង្កើនសុវត្ថិភាពចរាចរណ៍

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានសហការគ្នាជាយូរមកហើយជាមួយរាជរដ្ឋាភិបាលកម្ពុជា លើការឆ្លើយតបនឹងគ្រោះមហន្តរាយ ភាពធន់ ការស្តារឡើងវិញ និងផែនការយុទ្ធសាស្ត្រដែលផ្តោតសំខាន់លើការដឹកជញ្ជូន។

យុទ្ធសាស្ត្រវិស័យដឹកជញ្ជូនរបស់ ADB សម្រាប់ប្រទេសជាសមាជិក រួមទាំងកម្ពុជា ផ្តោតសំខាន់លើ ៖

- ការពង្រឹងកិច្ចសហប្រតិបត្តិការបច្ចេកទេស ការកំណត់ស្តង់ដារ និងការវិនិយោគដោយវិស័យឯកជនលើវិស័យដឹកជញ្ជូន
- ការគាំទ្រដល់គម្រោងអនុតំបន់ដែលត្រូវបានជ្រើសរើស ដែលលើកកម្ពស់លទ្ធភាពចូលដល់តំបន់ជនបទ ការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងដែន និងការពង្រឹងពាណិជ្ជកម្មក្នុងមហាអនុតំបន់ទន្លេមេគង្គ និងការគាំទ្រផ្នែកភស្តុភារ

រូបភាពទី ២ បង្ហាញពីភាពចាំបាច់នៃការពិនិត្យឡើងវិញលើចក្ខុវិស័យនៃការស្តារវិស័យផ្លូវថ្នល់ឡើងវិញ ដោយផ្អែកលើការពិនិត្យឡើងវិញលើការប្រែប្រួលតម្រូវការ និងចក្ខុវិស័យរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ និងទីភ្នាក់ងារអន្តរជាតិ។




រូបភាពទី ២ ៖ ធាតុចូលក្នុងចក្ខុវិស័យស្តារឡើងវិញរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ (ការបកស្រាយរបស់អ្នកនិពន្ធ)

## គោលការណ៍ណែនាំសម្រាប់ការស្តារឡើងវិញ

សម្រាប់វិស័យផ្លូវថ្នល់នៅកម្ពុជា គេអាចប្រើប្រាស់គោលការណ៍ណែនាំខាងក្រោម (ដកស្រង់ចេញពីគោលការណ៍ណែនាំទូទៅសម្រាប់កម្ពុជាស្តីពីកំណើន និងការស្តារឡើងវិញ តាមរយៈការពិនិត្យឡើងវិញលើឯកសារពាក់ព័ន្ធ) ជាត្រីវិស័យសម្រាប់ការរៀបចំផែនការស្តារឡើងវិញ (GFDRR, 2018)៖

- **កាត់បន្ថយហានិភ័យ** ៖ តាមរយៈការប្តូរទីតាំងរចនាសម្ព័ន្ធដឹកជញ្ជូនពីតំបន់ដែលមានហានិភ័យខ្ពស់ ឬការកែលម្អរចនាសម្ព័ន្ធដឹកជញ្ជូនឱ្យប្រសើរឡើងដើម្បីកាត់បន្ថយភាពងាយរងគ្រោះ។
- **បង្កើនភាពងាយស្រួល និងចល័តភាព** ៖ ផ្តល់លទ្ធភាពចេញចូលសហគមន៍នៅក្នុងតំបន់ដែលបច្ចុប្បន្នមិនអាចចេញចូលបាន (ដោយសារគ្រោះមហន្តរាយ ឬស្ថានភាពសង្គម) នឹងទ្រទ្រង់ឱកាសការងារ លទ្ធភាពទទួលបានសេវាសំខាន់ៗ និងកំណើនសេដ្ឋកិច្ចជារួម។
- **អនុវត្តដំណោះស្រាយបៃតង និងឆ្លាតវៃអាកាសធាតុ** ៖ កំណត់រកឱកាសដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីវិស័យផ្លូវថ្នល់ ជាវិធីផ្ទាល់មួយនៃការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងឈានទៅកាត់បន្ថយហានិភ័យ។
- **រិះរកដំណោះស្រាយដែលចំណាយតិច និងទទួលបានលទ្ធផលខ្ពស់** ៖ សម្រាប់សេដ្ឋកិច្ចដែលមិនសូវទទួលបានជំនួយមូលធន កិច្ចខិតខំប្រឹងប្រែងបែបនវានុវត្តន៍ក្នុងដំណោះស្រាយដែលចំណាយតិច ជាគន្លឹះក្នុងការពន្លឿនដំណើរការស្តារឡើងវិញ។
- **សំឡឹងឆ្ពោះទៅអនាគត** ៖ បន្សីកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញឱ្យស្របទៅនឹងគោលដៅរយៈពេលវែងរបស់កម្ពុជា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ការបង្កើតវដ្តវិជ្ជមាននៃការផ្តល់ជំនួយដល់ និងការទទួលបានជំនួយពីប្រព័ន្ធថ្នាក់ជាតិ។
- **ផ្តោតសំខាន់លើសមធម៌ និងបរិយាបន្ន** ៖ បញ្ចូលទស្សនៈយល់ឃើញរបស់សមាជិកសហគមន៍ទាំងអស់ដែលរងផលប៉ះពាល់ដោយសារវិស័យផ្លូវថ្នល់ និងការប្រែប្រួលក្នុងវិស័យនេះ និងខិតខំបង្កើតឱកាសការងារ និងទីផ្សារសម្រាប់មនុស្សគ្រប់រូប។
- **ផ្តោតសំខាន់លើប្រសិទ្ធភាព** ៖ បំពេញតម្រូវការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យចល័តភាពរបស់មនុស្ស និងទំនិញកាន់តែមានភាពរលូន។
- **បង្កើនសុវត្ថិភាព** ៖ ប្រើប្រាស់ព្រឹត្តិការណ៍វាំងស្ទះជាមូលដ្ឋាននៃការបង្កើនសុវត្ថិភាពផ្លូវថ្នល់នាពេលអនាគត
- **កសាងឡើងវិញឱ្យកាន់តែប្រសើរ** ៖ ផ្អែកតាមគោលការណ៍ទូទៅនៃការស្តារឡើងវិញ ប្រើប្រាស់ឱកាសស្ថាបនាឡើងវិញជាមធ្យោបាយសម្រាប់ការកែលម្អប្រព័ន្ធនេះ និងកាត់បន្ថយភាពខ្វះខាតនៃប្រព័ន្ធដឹកជញ្ជូនដែលបានកំណត់កន្លងមក។

កម្មវិធី និងគម្រោងស្តារឡើងវិញនីមួយៗ ចាំត្រូវអនុវត្តតាមគោលការណ៍ណែនាំយ៉ាងតិចមួយក្នុងចំណោមគោលការណ៍ណែនាំខាងក្រោម ៖

ភាពចាំបាច់នៃការកែសម្រួលឡើងវិញក្រោយពេលមានគ្រោះមហន្តរាយធ្ងន់ធ្ងរ

ខណៈដែលចក្ខុវិស័យ និងគោលការណ៍សម្រាប់ការស្តារវិស័យផ្លូវថ្នល់ឡើងវិញ នឹងមិនប្រែប្រួលក្នុងអំឡុងពេលសមស្របមួយ វាជាការសំខាន់ដែលត្រូវធ្វើការពិនិត្យឡើងវិញតាមដំណាក់កាលលើចក្ខុវិស័យ និងគោលការណ៍ទាំងនេះ ដើម្បីឱ្យដឹងថាតើវាមានការប្រែប្រួលក្រោយពេលមានគ្រោះមហន្តរាយ ឬទេ។

ក្រោយពេលមានគ្រោះមហន្តរាយ សូមពិនិត្យចំណុចខាងក្រោម ៖

១ តើមានគម្លាតធំ (>១០ ឆ្នាំ) រវាងការអភិវឌ្ឍចក្ខុវិស័យនេះ និងការកើតឡើងនៃគ្រោះមហន្តរាយនោះឬទេ?

**និង/ឬ**

២ តើមានការប្រែប្រួលខ្លាំងក្នុងគោលដៅជារួមរបស់កម្ពុជា ឬគោលដៅជារួមនៃវិស័យផ្លូវថ្នល់ ឬទេ?

៣ ប្រសិនបើឆ្លើយថា "មែន" សម្រាប់សំណួរទី ១ ឬទី ២ សូមពិនិត្យឡើងវិញលើចក្ខុវិស័យស្តារឡើងវិញ ដោយផ្អែកលើក្រាហ្វបង្ហាញក្នុងរូបភាពទី ៤ និងធ្វើការកែប្រែចាំបាច់។ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ គួរដឹកនាំការពិនិត្យឡើងវិញនេះ។

ការពិនិត្យឡើងវិញលើចក្ខុវិស័យបច្ចុប្បន្នភាពសម្រាប់ការស្តារវិស័យផ្លូវថ្នល់ឡើងវិញ ដោយភាគីពាក់ព័ន្ធសំខាន់ៗ ដូចជា រាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និង គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ និងទីភ្នាក់ងារអន្តរជាតិ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី។

## កម្មវិធីស្តារវិស័យផ្លូវថ្នល់ឡើងវិញ

អ្វីដែលចាំបាច់គឺត្រូវបន្តប្រែក្លាយផែនការស្តារឡើងវិញដែលត្រូវបានបង្កើតឡើង ដោយផ្អែកលើតម្រូវការស្តារឡើងវិញដែលបានកំណត់ក្នុងដំណើរការ PDNA ទៅជាកម្មវិធីដែលអនុវត្តបាន។ កម្មវិធីទាំងនេះគួរតែបានកំណត់ព្រំដែន ធាតុចូល ចំណុចដៅ និងលទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយដែលបានកំណត់ទុកជាមុន។

ត្រូវចាំថា វិស័យផ្សេងៗនឹងប្រជែងគ្នាច្បាមយកធនធានដែលមានដើម្បីបញ្ចប់កម្មវិធីស្តារឡើងវិញរបស់ខ្លួន។ ដោយសារតែវិស័យដឹកជញ្ជូនពាក់ព័ន្ធនឹងវិស័យផ្សេងទៀត (សង្គម ផលិតកម្ម និងហេដ្ឋារចនាសម្ព័ន្ធ) មន្ត្រីផ្នែកដឹកជញ្ជូនចាំបាច់ត្រូវលើកឡើងពីភាពប្រទាក់ក្រឡាគ្នា និងធ្វើការជាមួយវិស័យផ្សេងទៀតដើម្បីសម្រេចបានលទ្ធផលនៃការស្តារឡើងវិញឱ្យបានជាទីគាប់ចិត្ត។ រូបភាពទី ៣ បង្ហាញពីវិស័យពាក់ព័ន្ធក្នុងផ្នែកផលិតកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងសង្គមដែលមានភាពចម្រូងចម្រាស់គ្នា ក្នុងអំឡុងពេលអនុវត្តក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ។ ដូចការគូសបញ្ជាក់ វិស័យដឹកជញ្ជូនជះឥទ្ធិពលលើវិស័យផលិតកម្ម និងវិស័យសង្គមទាំងអស់។ ដូច្នេះ គួរបង្កើតកម្មវិធីបែបសហការដែលបម្រើឱ្យវិស័យទាំងពីរនេះ។




រូបភាពទី ៣ ៖ ទំនាក់ទំនងរវាងវិស័យដឹកជញ្ជូន និងវិស័យសំខាន់ៗផ្សេងទៀត

កម្មវិធីស្តារឡើងវិញដឹកនាំដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ និងគួរកំណត់ជំហានសកម្មភាព ដើម្បីឱ្យតម្រូវការស្តារឡើងវិញបន្សុីគ្នានឹងចក្ខុវិស័យ និងគោលការណ៍ណែនាំដែលបានកំណត់ពីមុនមក។

ការអភិវឌ្ឍកម្មវិធីស្តារឡើងវិញសម្រាប់វិស័យផ្លូវថ្នល់ គួរអនុវត្តតាមជំហានខាងក្រោម ៖

- កំណត់តម្រូវការអាទិភាពខ្ពស់បំផុតនៃវិស័យផ្លូវថ្នល់ ដោយផ្អែកលើការខូចខាតរបស់ប្រព័ន្ធនេះ (លទ្ធផល PDNA)
- កំណត់ទីតាំងភូគព្ភរូបវន្តដែលត្រូវកំណត់យកជាអាទិភាព ដោយផ្អែកលើសារៈសំខាន់នៃទីតាំងទាំងនោះសម្រាប់សេដ្ឋកិច្ចកម្ពុជា និងលទ្ធភាពទូទៅក្នុងការទទួលបានសេវាសំខាន់ៗ
- រៀបលំដាប់កំណាត់ផ្លូវដែលត្រូវស្តារឡើងវិញ ដោយផ្អែកលើអាទិភាពដែលបានកំណត់
- ពិគ្រោះជាមួយអ្នកជំនាញ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីកំណត់រកដំណោះស្រាយ ដោយផ្អែកតាមតំបន់ និងតម្រូវការដែលបានកំណត់។ ក្រុមភាគីពាក់ព័ន្ធសំខាន់ៗ (ក្រៅពីក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ) រួមមាន ៖
  - វិស័យសាធារណៈ ៖ ក្រសួងសាម៉ីរបស់វិស័យដែលមានទំនាក់ទំនងជាមួយវិស័យផ្លូវថ្នល់ (សូមមើលរូបភាពទី ៤)
  - វិស័យសង្គម ៖ សហគមន៍ដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយ និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ទាំងនេះ (សម្រាប់តារាងឈ្មោះដៃគូវិស័យសង្គមក្នុងការស្តារឡើងវិញពីគ្រោះមហន្តរាយនៅកម្ពុជា សូមមើលប្រអប់ទី ៤ ក្នុងផ្នែក "ការរៀបចំផ្នែកស្ថាប័នសម្រាប់វិស័យផ្លូវថ្នល់")។
- ពិនិត្យឡើងវិញលើដំណោះស្រាយដែលបានកំណត់សម្រាប់ការធានាសុវត្ថិភាពសង្គម និងបរិស្ថាន ដើម្បីធានាថា គម្រោងមិនបង្កអន្តរាយក្នុងតំបន់ទាំងនេះ។

ជាទូទៅ ដំណោះស្រាយវិស្វកម្មសម្រាប់ការស្តារវិស័យផ្លូវថ្នល់ដែលមានភាពធន់ ត្រូវផ្តោតសំខាន់លើ ៖

- ស្ថានភាពក្រោមផ្ទៃដី
- យថាប្រភេទសម្ភារ
- មុខកាត់ និងវិមាត្រស្តង់ដារ
- ការបង្ហូរទឹក និងសំណឹក
- រចនាសម្ព័ន្ធការពារផ្នែកវិស្វកម្ម

គេអាចប្រើប្រាស់គម្លាតដែលបានកត់សម្គាល់ក្នុងវិស័យដឹកជញ្ជូនតាមរយៈការសិក្សានានា ជាសំណុំទិន្នន័យដើម្បីជាជំនួយដល់ការកំណត់អាទិភាពតម្រូវការ។ ឧ. ប្រអប់ទី ២ បង្ហាញពីដើមឈើបញ្ហាសម្រាប់វិស័យដឹកជញ្ជូននៅកម្ពុជា ដែលជាផ្នែកមួយនៃការបង្កើតឯកសារវាយតម្លៃវិស័យដឹកជញ្ជូននៅកម្ពុជា យុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវ ដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB, 2019)។

## ប្រអប់ទី ២ ៖ ដើមឈើបញ្ហាសម្រាប់វិស័យដឹកជញ្ជូននៅកម្ពុជា ( ADB, 2019 )

**ផលប៉ះពាល់នៅថ្នាក់ជាតិ**

- កង្វះការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ និងសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចអនុតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ

**ផលប៉ះពាល់តាមវិស័យ**

- កង្វះបណ្តាញផ្លូវថ្នល់ដែលធន់នឹងគ្រប់ស្ថានភាពធាតុអាកាសនៅថ្នាក់ជាតិ ទីជនបទ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ
- កង្វះភាពប្រកួតប្រជែងដែលបណ្តាលឱ្យមានចំណាយខ្ពស់ផ្នែកភស្តុភារ
- ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដែលមិនមានសុវត្ថិភាព និងនិរន្តរភាព

**បញ្ហាស្នូលក្នុងវិស័យ**

- កង្វះការតភ្ជាប់ និងអប្រសិទ្ធភាពក្នុងវិស័យដឹកជញ្ជូន

**បញ្ហាសំខាន់ៗ**

1. កង្វះគោលនយោបាយវិស័យដែលត្រូវបានកែសម្រួល និងការអនុវត្តច្បាប់ដោយប្រសិទ្ធភាព
2. កង្វះការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធមួយចំនួនដើម្បីបំពេញតម្រូវការថ្នាក់ជាតិ និងថ្នាក់តំបន់
3. កង្វះនិរន្តរភាពក្នុងផ្នែកសង្គម បរិស្ថាន និងហិរញ្ញវត្ថុ

**បញ្ហាតាមវិស័យ ហានិភ័យ និងការសន្មត**

### 1. កង្វះគោលនយោបាយវិស័យដែលត្រូវបានកែសម្រួល និងការអនុវត្តច្បាប់ដោយប្រសិទ្ធភាព

**បញ្ហាតាមវិស័យ**

- គោលនយោបាយផ្លូវការសម្រាប់វិស័យដឹកជញ្ជូនមិនមែនជាអាទិភាព
- កង្វះយុទ្ធសាស្ត្រសម្រាប់ការកំណត់អាទិភាពគម្រោង
- កង្វះការសម្របសម្រួលដល់ការរៀបចំផែនការវិស័យដឹកជញ្ជូន
- កង្វះការអនុវត្តច្បាប់ ( ឧ. ច្បាប់ស្តីពីផ្លូវថ្នល់ )
- ការកសាងសមត្ថភាពសម្រាប់ដំណើរការតាមលំដាប់លំដោយរយៈពេលវែង
- មិនទាន់អនុវត្តកិច្ចព្រមព្រៀងផ្លូវថ្នល់តាមព្រំដែនសម្រាប់មហាអនុតំបន់ទន្លេមេគង្គ
- មិនទាន់បំពេញកិច្ចព្រមព្រៀងផ្លូវដែកតាមព្រំដែនសម្រាប់មហាអនុតំបន់ទន្លេមេគង្គ
- ទាមទារច្បាប់ និងបទបញ្ញត្តិសម្រាប់វិស័យឯកជន

**ហានិភ័យ និងការសន្មត**

- កង្វះការផ្តោតលើលក្ខខណ្ឌតម្រូវផ្នែកគោលនយោបាយ
- មិនមានការបណ្តុះបណ្តាលជំនាញតាមស្ថាប័ន
- មិនរក្សាទុកបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល
- កង្វះកិច្ចព្រមព្រៀងឆ្លងដែនជាមួយប្រទេសជិតខាង
- ការវិនិយោគលើវិស័យដឹកជញ្ជូនដោយវិស័យឯកជនលើសពីសមត្ថភាពរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

### 2. កង្វះការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធមួយចំនួនដើម្បីបំពេញតម្រូវការថ្នាក់ជាតិ និងថ្នាក់តំបន់

**បញ្ហាតាមវិស័យ**

- កង្វះចិញ្ចើមផ្លូវសម្រាប់ផ្លូវជាតិ និងផ្លូវខេត្តដើម្បីបំពេញតម្រូវការចរាចរណ៍
- កង្វះបណ្តាញផ្លូវក្នុងមូលដ្ឋានដែលត្រូវបានចាក់ក្រាលនិងធន់នឹងគ្រប់ធាតុអាកាស
- ភាពខ្វះចន្លោះនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងមហាអនុតំបន់ទន្លេមេគង្គ
- កង្វះការផ្តោតសំខាន់លើហេដ្ឋារចនាសម្ព័ន្ធពហុទម្រង់
- កង្វះមធ្យោបាយដឹកជញ្ជូនសាធារណៈក្នុងទីប្រជុំជន
- កង្វះលទ្ធភាពទទួលបានមធ្យោបាយដឹកជញ្ជូនសាធារណៈ
- កង្វះយន្តការសម្រាប់ការប្រកួតប្រជែង តម្លាភាព និងគណនេយ្យភាពក្នុងដំណើរការលទ្ធកម្ម និងប្រតិបត្តិការសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន

**ហានិភ័យ និងការសន្មត**

- មិនសូវមានការសម្របសម្រួលក្នុងចំណោមដៃគូអភិវឌ្ឍន៍លើការរៀបចំផែនការវិនិយោគ
- កង្វះការភ្ជាប់បណ្តាញដឹកជញ្ជូនឆ្លងព្រំដែនអន្តរជាតិ និងមិនមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឆ្លងដែន
- ការអនុវត្តគម្រោងមានភាពយឺតយ៉ាវ និងមិនគ្រប់គ្រាន់
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមិនមានភាពទាក់ទាញសម្រាប់វិស័យឯកជន

### 3. កង្វះនិរន្តរភាពក្នុងផ្នែកសង្គម បរិស្ថាន និងហិរញ្ញវត្ថុ

**បញ្ហាតាមវិស័យ**

- កង្វះប្រព័ន្ធជួសជុលបណ្តាញផ្លូវជាតិ និងផ្លូវក្នុងមូលដ្ឋាន
- កង្វះការចូលរួមពីវិស័យឯកជន
- ភាពខ្វះចន្លោះនៃវិស្វកម្ម និងប្រតិបត្តិការចរាចរណ៍ តាមបណ្តាញផ្លូវហាយវេ
- កង្វះការទប់ស្កាត់ការកកស្ទះចរាចរណ៍
- កង្វះការអនុវត្តសមស្របនូវឧបករណ៍ ហាដវែរ និងវិធានការសុវត្ថិភាពចរាចរណ៍
- ឥរិយាបថមិនសមរម្យរបស់អ្នកបើកបរ និងអ្នកថ្មើរជើង
- ការធានាសុវត្ថិភាពធ្វើឡើងមិនបានគ្រប់គ្រាន់ និងមិនស៊ីសង្វាក់គ្នា។

**ហានិភ័យ និងការសន្មត**

- កង្វះតម្លាភាពក្នុងការដេញថ្លៃការងារសាងសង់
- កង្វះសមត្ថភាព និងការគ្រប់គ្រងគុណភាពក្នុងចំណោមអ្នកទទួលការសាងសង់ និងទីប្រឹក្សា
- កង្វះការកាត់បន្ថយស្ថានភាពផ្លូវដែលមិនមានសុវត្ថិភាព
- ឥរិយាបថមិនសមរម្យរបស់អ្នកប្រើប្រាស់ផ្លូវ
- កង្វះការពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញត្តិចរាចរណ៍
- ភាពខ្វះចន្លោះនៃដំណើរការផ្តល់ប័ណ្ណបើកបរ និងឆៀកយានយន្ត
- កង្វះការគាំទ្រពីក្រុមហ៊ុនផលិតម៉ូតូ

គេអាចគូសផែនទីបង្ហាញដើមឈើបញ្ហាក្នុងប្រអប់ ខ បូករួមនឹងបញ្ហាស្រដៀងគ្នាក្នុងវិស័យផ្លូវថ្នល់ដែលបានកត់សម្គាល់តាំងពីឆ្នាំ ២០១៩ អមជាមួយនឹងតម្រូវការស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ និងអាចទាញប្រយោជន៍ពីគំនិតផ្តួចផ្តើមដែលបានធ្វើឡើងដើម្បីដោះស្រាយបញ្ហាដែលបានកត់សម្គាល់ ដើម្បីទ្រទ្រង់គម្រោងស្តារឡើងវិញ។ ឱ. ផែនទីបង្ហាញផ្លូវនេះកំណត់រកគម្រោងចម្រុះដែលកំពុងអនុវត្ត និងគម្រោងនាពេលអនាគត ដើម្បីដោះស្រាយបញ្ហាទាំងនេះ (ដូចជា កម្មវិធីផ្តល់កម្ចីដល់គម្រោងសម្រាប់ការកែលម្អផ្លូវថ្នល់ និងកម្មវិធីកសាងសមត្ថភាពសម្រាប់ក្រសួងសាធារណការ និងដឹកជញ្ជូន)។ កម្មវិធីមានស្រាប់ទាំងនេះអាចផ្តល់មូលដ្ឋានសម្រាប់ការចាប់ផ្តើមកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ។

បេសកកម្មស្វែងរកការពិតក្នុងឆ្នាំ ២០១០ ដែលពាក់ព័ន្ធនឹងភាពងាយរងគ្រោះនៃវិស័យផ្លូវថ្នល់នៅកម្ពុជា បានកំណត់ភាពងាយរងគ្រោះជាក់លាក់ក្នុងតំបន់សំខាន់ៗ ៣ ៖ បណ្តាញផ្លូវថ្នល់ក្នុងខេត្តកំពង់ធំងាយរងគ្រោះដោយសារការហូរច្រោះដោយទឹក ដែលបង្កជាបញ្ហាសុខភាពធ្ងន់ធ្ងរនៅខ្សែទឹកខាងក្រោម ពេលគឺមានការហុយធូលីនៅរដូវប្រាំង និងមានការហូរច្រោះដោយទឹកនៅរដូវវស្សា។ ដូច្នេះ ការចាក់ក្រាលកំណាត់ផ្លូវ ទន្ទឹមនឹងការពិចារណាពីការរចនាផ្លូវដើម្បីធានាការបង្ហូរទឹកចេញឱ្យបានសមស្រប ជាចំណុចសំខាន់សម្រាប់តំបន់នេះ។ ផ្លូវថ្នល់ក្នុងខេត្តកំពង់ស្ពឺត្រូវការគម្របសារពើរុក្ខជាតិនៅលើទំនប់ការពារទឹកដើម្បីទប់ស្កាត់សំណឹក។ ផ្លូវថ្នល់ក្នុងខេត្តពោធិ៍សាត់ ស្ថិតក្នុងតំបន់ទឹកជំនន់ និងទំនាប ដែលធ្វើឱ្យខេត្តនេះងាយប្រឈមនឹងគ្រោះទឹកជំនន់។ ដូច្នេះ ការលើកកម្ពស់កំណាត់ផ្លូវក្នុងតំបន់នេះគួរតែជាអាទិភាពចម្បង។

ការផ្គូរផ្គងតម្រូវការស្តារឡើងវិញក្នុង PDNA ឱ្យត្រូវគ្នានឹងគម្លាតដែលបានកំណត់រួចជាស្រេចក្នុងវិស័យផ្លូវថ្នល់នៅកម្ពុជា អាចនាំឱ្យមានការច្របាច់បញ្ចូលគ្នានូវកិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់ និងកម្មវិធីស្តារឡើងវិញទៅតាមស្ថានភាពគ្រោះមហន្តរាយ។

ផ្អែកតាម PDNA កន្លងមក និងយុទ្ធសាស្ត្រស្តារឡើងវិញដែលបានលើកឡើងសម្រាប់វិស័យផ្លូវថ្នល់នៅកម្ពុជា គេអាចពិចារណាពីដំណោះស្រាយខាងក្រោម ៖

- ធ្វើទំនើបកម្មតាមបែបសំយោគលើរចនាសម្ព័ន្ធមានស្រាប់នៃផ្លូវដែលមានកម្រាស់ស្តើង (low-level) ដោយចាក់កម្រាស់បន្ថែមឱ្យបាន ០,៥ ម៉ែត្រ (ឬទៅតាមកម្រាស់ដែលកំណត់ដោយអ្នកជំនាញ ដោយយោងទៅតាមសេណារីយ៉ូនៃតំបន់ទំនាបលិចទឹក និងការកើនឡើងនៃនីវ៉ូទឹកសមុទ្រ ក្រោយពេលមានគ្រោះមហន្តរាយ)

- ការបន្ថែមថ្មមិចទៅក្នុងគ្រឹះផ្លូវ (adding a crushed stone base course) ដែលប្រសិនបើត្រូវបានធ្វើឡើងក្នុងកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញរយៈពេលមធ្យម នឹងសម្រួលដល់ការចាក់បេតុងកៅស៊ូ (Asphalt concrete) នាពេលអនាគតសម្រាប់ផ្លូវក្នុងក្រុង ផ្លូវជាតិ និងផ្លូវខេត្ត និងផ្លូវក្រាលកៅស៊ូ DBST សម្រាប់ផ្លូវនៅជនបទ។

- ការកែលម្អជម្រាលផ្លូវ នៅកំណាត់ផ្លូវដែលជម្រាលមិនស្មើគ្នាអាចបង្កជាហានិភ័យខ្ពស់ ៖ ស្តង់ដារជម្រាលផ្លូវបច្ចុប្បន្នគឺមិនលើស ១:២ ដែលអាចបង្កើនដល់ ១:៣ សម្រាប់ផ្លូវដែលលំបាកធ្វើដំណើរ និងងាយបង្កគ្រោះថ្នាក់ (រាជរដ្ឋាភិបាលកម្ពុជា, 2010)។

- ការដាក់បញ្ចូលដំណោះស្រាយដែលផ្អែកតាមកត្តាធម្មជាតិ ដូចជា ការដាំដើមឈើដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅតាមខឿនផ្លូវ។

## ការរៀបចំផែនការប្រើប្រាស់ដីធ្លី

ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនត្រូវបានរចនាឡើងដើម្បីធានាការប្រើប្រាស់រាប់ទសវត្សរ៍។ រចនាសម្ព័ន្ធដឹកជញ្ជូនក៏ដើរតួនាទីសំខាន់ផងដែរក្នុងការកំណត់គំរូនៃការប្រើប្រាស់ដីធ្លី។ ឧ. នៅកម្ពុជា ការតភ្ជាប់តំណផ្លូវ និងការបង្កើនគុណភាពផ្លូវក្នុងច្រករបៀងមហាអនុតំបន់ទន្លេមេគង្គ (GMS) នឹងបង្កើនសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់នេះ ដែលនឹងជំរុញឱ្យមានលំហូរប្រជាជនកាន់តែច្រើនចូលមកក្នុងតំបន់នេះ និងបង្កើនតម្រូវការអភិវឌ្ឍន៍លំនៅដ្ឋាន និងការប្រើប្រាស់ដីធ្លីផ្សេងទៀត។ ដូច្នេះ ចំណុចសំខាន់គឺនៅពេលស្ថាបនាផ្លូវឡើងវិញ ចាំបាច់ត្រូវពិនិត្យថាតើគ្រោះមហន្តរាយបានផ្លាស់ប្តូរគំរូនៃការប្រើប្រាស់ដីធ្លី ឬទេ ដើម្បីកាត់បន្ថយហានិភ័យនៃការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនអចិន្ត្រៃយ៍ឡើងវិញដែលបង្កផលជះអវិជ្ជមាន និងធ្វើឱ្យមានការប្រើប្រាស់ដីធ្លីមិនបានសមស្របនាពេលអនាគត។ ក្រុមការងារក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ផ្តោតសំខាន់លើតម្រូវការស្តារឡើងវិញ ដើម្បីកំណត់ថាតើគួរពិចារណាពីផែនការប្រើប្រាស់ដីធ្លីមុនពេលអនុវត្តគម្រោង ឬទេ។

ខាងក្រោមនេះជាចំណុចសំខាន់ៗដែលត្រូវពិចារណាក្រោយពេលមានគ្រោះមហន្តរាយ ៖

- តើថ្មីៗនេះ មានការប្រែប្រួលគំរូនៃការប្រើប្រាស់ដីធ្លី មុនពេលមានគ្រោះមហន្តរាយ ឬទេ ?
- ឧ. បំលាស់ទីប្រជាជនពីទីជនបទទៅទីប្រជុំជន ឬពីទីប្រជុំជនមួយទៅទីប្រជុំជនផ្សេងទៀត ដោយសារការប្រែប្រួលចរន្តសេដ្ឋកិច្ច។
- តើគ្រោះមហន្តរាយបណ្តាលឱ្យមានការប្រែប្រួលយ៉ាងខ្លាំងនៃគំរូប្រើប្រាស់ដីធ្លី ឬទេ ?
- ឧ. ការតាំងទីលំនៅថ្មីជាអចិន្ត្រៃយ៍របស់សហគមន៍នៅក្រៅតំបន់មួយ ?
- តើកម្មវិធីស្តារឡើងវិញដែលបានកំណត់ ធ្វើឱ្យមានការប្រែប្រួលគំរូនៃការប្រើប្រាស់ដីធ្លី ឬទេ ?
- ឧ. ការសម្រេចផ្លាស់ទីតាំងផ្លូវដ៏សំខាន់មួយ ដោយសារការកើនឡើងនៃហានិភ័យគ្រោះមហន្តរាយ អាចធ្វើឱ្យប៉ះពាល់ដល់គំរូនៃការអភិវឌ្ឍតំបន់លំនៅដ្ឋាន និងតំបន់ស្ថាបនាផ្លូវ (work zone) នាពេលអនាគត។
- ប្រសិនបើដូច្នេះមែន សូមធ្វើការវាយតម្លៃដោយប្រុងប្រយ័ត្នថា ការប្រែប្រួលគំរូនៃការប្រើប្រាស់ដីធ្លីដែលអាចកើតឡើង មិនបង្កផលប៉ះពាល់អវិជ្ជមានលើប្រជាជនដែលងាយរងគ្រោះ (ការកាត់ផ្តាច់ ឬការកាត់បន្ថយការចេញចូលតំបន់ស្ថាបនាផ្លូវ និងលទ្ធភាពទទួលបានសេវាសំខាន់ៗសម្រាប់សហគមន៍មួយចំនួន)។

## ការរៀបចំផ្នែកស្ថាប័នសម្រាប់ការស្តារវិស័យផ្លូវថ្នល់ឡើងវិញ

ដើម្បីអភិវឌ្ឍ អនុវត្ត វាយតម្លៃ និងលើកកម្ពស់ផែនការ កម្មវិធី និងគោលនយោបាយស្តារឡើងវិញប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវកំណត់ និងបញ្ជ្រាបការរៀបចំផ្នែកស្ថាប័ន។ ការបញ្ជាក់ពីការរៀបចំផ្នែកស្ថាប័ន និងការកំណត់ច្បាស់ពីតួនាទី/ការទទួលខុសត្រូវ ជាកត្តាសំខាន់ទាំងនៅថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន និងថ្នាក់សហគមន៍។

នៅកម្ពុជា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ដឹកនាំមុខងារសម្របសម្រួលដែលផ្តោតសំខាន់លើការត្រៀមខ្លួនទប់ទល់គ្រោះមហន្តរាយ ជំនួយសង្គ្រោះបន្ទាន់ និងការសម្របសម្រួលរវាងក្រសួងពាក់ព័ន្ធ និងសហគមន៍ម្ចាស់

ជំនួយ។ ក្រសួងពាក់ព័ន្ធតាមវិស័យ (សម្រាប់វិស័យផ្លូវថ្នល់គឺក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ) ទទួលខុសត្រូវ លើការអនុវត្តអន្តរាគមន៍ជាក់លាក់ក្នុងផ្នែករចនាសម្ព័ន្ធ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការស្តារ និងស្តាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលរងការខូចខាត (ADB, 2014)។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ជាស្ថាប័នដែលត្រូវបានបង្កើតឡើងដើម្បីដឹកនាំ ការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា។ គណៈកម្មាធិការនេះធ្វើជាប្រធានដោយនាយករដ្ឋមន្ត្រី និងចូលរួមដោយរដ្ឋមន្ត្រីនៃក្រសួងនីមួយៗ រួមជាមួយនឹងកងយុទ្ធពលខេមរភូមិន្ទ កាកបាទក្រហមកម្ពុជា និងអាជ្ញាធរអាកាសចរស៊ីវិល (ADB, 2014)។ បន្ទាប់មក ការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានផ្ទេរវិមជ្ឈការទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ស្រុក និងឃុំ។ ក្របខ័ណ្ឌស្ថាប័នសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ មានបង្ហាញក្នុងរូបភាពទី ៤។ សម្រាប់វិស័យផ្លូវថ្នល់ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ តំណាងដោយក្រុមការងាររបស់ក្រសួង និងដឹកនាំការស្តារវិស័យផ្លូវថ្នល់។




រូបភាពទី ៤ ៖ ក្របខ័ណ្ឌស្ថាប័នសម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅកម្ពុជា

ក្រសួងសាធារណការ និងដឹកជញ្ជូន មាននាយកដ្ឋានសំខាន់ៗជាច្រើនដែលមានតួនាទីពាក់ព័ន្ធក្នុងការស្តារវិស័យផ្លូវថ្នល់ឡើងវិញ។ ខាងក្រោមនេះជានាយកដ្ឋានសំខាន់ៗ ដែលមានបង្ហាញក្នុងរូបភាពទី ៥ ៖

អគ្គនាយកដ្ឋានបច្ចេកទេស ៖

- នាយកដ្ឋានផ្លូវថ្នល់
- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- នាយកដ្ឋានបច្ចេកទេសសាធារណការ និងដឹកជញ្ជូន
- វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន

### អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក

- នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
- នាយកដ្ឋានសុវត្ថិភាពចរាចរណ៍
- នាយកដ្ឋានដឹកជញ្ជូនសាធារណៈក្រុង

### អគ្គនាយកដ្ឋានសាធារណការ

- នាយកដ្ឋានផ្លូវល្បឿនលឿន ស្ពាន និង វិនិយោគ
- នាយកដ្ឋានគ្រឿងចក្រ និងស្ពាបនាផ្លូវ
- នាយកដ្ឋានជួសជុល និងថែទាំផ្លូវ

### អគ្គាធិការដ្ឋាន

- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្តទាំងអស់ដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយ




រូបភាពទី ៥ ៖ អង្គការលេខរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន-នាយកដ្ឋានដែលមានពណ៌ហាយឡាយក្រហម ជានាយកដ្ឋានពាក់ព័ន្ធក្នុងការរៀបចំផែនការក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ

# កំណត់បញ្ញត្តិ និងបញ្ជាក់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវ និងបង្កើតក្របខ័ណ្ឌប្រតិបត្តិ

ដោយសារតែក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ជាស្ថាប័នចម្បងពីរដែលដឹកនាំការស្តារវិស័យផ្លូវថ្នល់នៅកម្ពុជា វាជាការសំខាន់ដែលត្រូវកំណត់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងទាំងនេះក្នុងអំឡុងពេលស្តារឡើងវិញពីគ្រោះមហន្តរាយ។

ដើម្បីអភិវឌ្ឍក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយដែលមានប្រសិទ្ធភាព ក្រសួងទាំងពីរចាំបាច់ត្រូវចាត់តាំងមន្ត្រីមួយរូប (មកពីក្រសួងសាធារណការ និងដឹកជញ្ជូន) ឱ្យដឹកនាំការស្តារផ្លូវជាតិ និងផ្លូវខេត្តឡើងវិញ និងមន្ត្រីមួយរូបទៀត (មកពីក្រសួងអភិវឌ្ឍន៍ជនបទ) ឱ្យដឹកនាំការស្តារផ្លូវជនបទឡើងវិញ។ វាជាការសំខាន់ដែលមន្ត្រីបង្គោលទាំងពីររូបនេះត្រូវទទួលបានការគោរពក្នុងឆាកនយោបាយ និងមានសមត្ថភាព។ ការដឹកនាំប្រកបដោយសមានចិត្តជាកត្តាសំខាន់ក្នុងការធានាភាពម្ចាស់ការផ្នែកនយោបាយ និងភាពម្ចាស់ការរបស់សហគមន៍ និងហិរញ្ញប្បទានសម្រាប់ការស្តារឡើងវិញ។

ក្រសួងសាមី និងមន្ត្រីបង្គោលទាំងពីររូបដែលត្រូវបានចាត់តាំងសម្រាប់ការងារស្តារឡើងវិញ គួរបង្កើតក្រុមការងារសម្របសម្រួលការស្តារវិស័យដឹកជញ្ជូនឡើងវិញ។ យកល្អគួរធ្វើយ៉ាងណាឱ្យក្រុមការងារនេះបន្សុីគ្នានឹងយន្តការសម្របសម្រួលការស្តារឡើងវិញនៅថ្នាក់ជាតិ តាមរយៈការរៀបចំកិច្ចប្រជុំរៀងរាល់ថ្ងៃពីដំបូង រួចឈានដល់កិច្ចប្រជុំរៀងរាល់សប្តាហ៍។ល។ ទៅតាមភាពសមស្របដើម្បីគាំទ្រដល់ការអនុវត្តផែនការស្តារឡើងវិញ។

ការទទួលខុសត្រូវរបស់ក្រុមការងារសម្របសម្រួលការស្តារវិស័យដឹកជញ្ជូនឡើងវិញ ៖

- ចាត់តាំងមន្ត្រីម្នាក់ឱ្យធ្វើជាប្រធានក្រុមការងារនេះ ដើម្បីរក្សាទំនាក់ទំនង និងការចូលរួមនៅកម្រិតខ្ពស់បំផុតជាមួយស្ថាប័នដឹកនាំការស្តារឡើងវិញជារួម
- សហការរៀបចំផែនការស្តារឡើងវិញសម្រាប់វិស័យផ្សេងទៀត និងប្រតិបត្តិការអនុវត្តន៍
- គាំទ្រការអនុវត្តបែបវិមជ្ឈការនៃសកម្មភាពស្តារឡើងវិញ តាមរយៈការបង្កើនភាពម្ចាស់ការក្នុងមូលដ្ឋាន និងការធ្វើសេចក្តីសម្រេចចិត្ត ជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត។
- ដើរតួនាទីជាមជ្ឈមណ្ឌលផ្លាស់ប្តូរព័ត៌មានស្តីពីការស្តារវិស័យដឹកជញ្ជូនឡើងវិញ
- បង្កើតការិយាល័យព័ត៌មានសាធារណៈដើម្បីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធ ដល់ប្រជាជនដែលរងផលប៉ះពាល់
- កាត់បន្ថយភាពត្រួតគ្នា ភាពច្រំដែល ឬអប្រសិទ្ធភាពក្នុងការស្តារវិស័យដឹកជញ្ជូនឡើងវិញ
- វិនិច្ឆ័យបណ្តឹង ការតវ៉ា និងការព្រួយបារម្ភផ្សេងទៀតរបស់ប្រជាជន និងក្រុមដែលរងផលប៉ះពាល់ ដោយដាក់បញ្ចូលពួកគេទៅក្នុងដំណើរការរៀបចំផែនការស្តារឡើងវិញ។

ប្រធានក្រុមការងារដែលត្រូវបានចាត់តាំងនេះ ត្រូវបង្កើតប្រព័ន្ធសម្រាប់គ្រប់គ្រងបុគ្គលិកក្នុងការងារស្តារឡើងវិញ។ កិច្ចការនេះអាចជាការលំបាក ព្រោះវាផ្អែកទៅតាមធម្មជាតិ និងវិសាលភាពនៃគ្រោះមហន្តរាយ។ ក្នុងករណីទាំងនេះ ការបង្កើតទំនាក់ទំនងជាស្រេចជាមួយភាគីពាក់ព័ន្ធខាងក្រៅ ដូចជា អង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានអប់រំ និងអង្គការអន្តរជាតិ នឹងបានជាប្រយោជន៍តាមរយៈការផ្តល់អ្នកជំនាញខាងក្រៅដើម្បីគាំទ្រដល់ដំណើរការរៀបចំផែនការស្តារឡើងវិញ។

# កំណត់បង្គោលចរ សម្រាប់ការប្រែក្លាយពីការស្តារឡើងវិញពីគ្រោះមហន្តរាយ ទៅជាការអភិវឌ្ឍក្រោយពេលមានគ្រោះមហន្តរាយ

ចុងបញ្ចប់ ដំណើរការធម្មតានឹងត្រូវបានបង្កើតឡើងវិញ។ ល្បឿននៃការស្តារឡើងវិញអាចថយចុះ និងអាចមានការបង្វែរមូលនិធិ ដែលធ្វើឱ្យមានការប្រជែងដណ្តើមធនធាន។ ជារឿយៗ កិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញមានរយៈពេល ១-៣ ឆ្នាំ នៅពេលដែលលែងមានមូលនិធិ និងការជួយសម្របសម្រួល ហើយការស្តារឡើងវិញត្រូវជាប់គាំង ដែលធ្វើឱ្យសហគមន៍ពាក់ព័ន្ធយល់ថា ពួកគេត្រូវបានបោះបង់ចោល។ ការសំខាន់គឺត្រូវរៀបចំផែនការទប់ទល់នឹងការថយចុះល្បឿននៃការស្តារឡើងវិញ កង្វះចំណាប់អារម្មណ៍ផ្នែកនយោបាយ និងមូលនិធិ និងបញ្ជ្រាបតាមស្ថាប័ននូវផ្នែកសំខាន់ៗនៃការស្តារឡើងវិញ ដើម្បីកុំឱ្យផ្នែកទាំងនោះពឹងផ្អែកទាំងស្រុងលើភាពបន្ទាន់។ ដើម្បីសម្រេចគោលបំណងនេះ គេត្រូវបង្កើតគោលការណ៍ណែនាំ និងបង្គោលចរច្បាស់លាស់សម្រាប់ការប្រែក្លាយពីការស្តារឡើងវិញពីគ្រោះមហន្តរាយ និងការស្ថាបនាឡើងវិញ ទៅជាការអភិវឌ្ឍក្រោយពេលមានគ្រោះមហន្តរាយ។



Photo: Phnom Penh Post, 03 December 2021

# យន្តការផ្តល់ហិរញ្ញប្បទានដល់វិស័យផ្លូវថ្នល់

ផ្នែកដ៏សំខាន់មួយនៃការអនុវត្តផែនការ និងកម្មវិធីស្តារឡើងវិញប្រកបដោយជោគជ័យ គឺការមានប្រភពមូលនិធិសម្រាប់ទ្រទ្រង់ការអនុវត្ត។ សម្រាប់វិស័យដឹកជញ្ជូន នេះជាកិច្ចការលំបាក ព្រោះការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនឡើងវិញត្រូវចំណាយច្រើន ជាពិសេសប្រសិនបើត្រូវកសាងឡើងវិញឱ្យកាន់តែប្រសើរសម្រាប់ការអភិវឌ្ឍដែលមានភាពធន់។ ដោយសារតែវិស័យផ្លូវថ្នល់ជាវិស័យសាធារណៈ មូលនិធិភាគច្រើនទទួលបានពីប្រភពសាធារណៈ។

ធាតុផ្សំសំខាន់ៗនៃការផ្តល់ហិរញ្ញប្បទានដល់ការស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ ៖

- ការកៀរគរធនធាន
- ការសម្របសម្រួល និងការបែងចែក
- លំហូរមូលនិធិ ចំណាយ និងគណនេយ្យ
- សវនកម្ម ការតាមដាន និងត្រួតពិនិត្យ

សម្រាប់ជាជំហានដំបូងក្នុងការស្នើសុំមូលនិធិ ក្រុមការងារវិស័យផ្លូវថ្នល់ត្រូវប្រើប្រាស់ការវាយតម្លៃការខូចខាត និងការបាត់បង់ពី PDNA ដើម្បីកសាងទឡ្ហីករណ៍មួយសម្រាប់ដាក់សំណើសុំមូលនិធិទៅបណ្តាញផ្សេងៗ។

រូបភាពទី ៦ ដកស្រង់ចេញពីរបាយការណ៍វិភាគការត្រៀមរៀបចំហិរញ្ញវត្ថុដើម្បីទប់ទល់នឹងគ្រោះមហន្តរាយ ដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងនាពេលថ្មីៗនេះរវាងធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការ UNDP ដើម្បីគាំទ្រដល់ការអភិវឌ្ឍការរៀបចំផែនការត្រៀមរៀបចំហិរញ្ញវត្ថុ និងសមត្ថភាពអនុវត្តថវិកាក្រោយពេលមានគ្រោះមហន្តរាយនៅកម្ពុជា (UNDP, 2022)។ រូបភាពនេះ




រូបភាពទី ៦ ៖ ហិរញ្ញប្បទានសម្រាប់ការស្តារឡើងវិញ ចេញពីជ្រុងថវិកាសម្រាប់កម្ពុជា (UNDP, 2022)

ត្រូវបានបង្កើតឡើងក្រោយការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដែលចូលរួមក្នុងការកំណត់ធនធានហិរញ្ញវត្ថុក្នុងការរៀបចំផែនការគ្រោះមហន្តរាយ សម្រាប់វិស័យផ្លូវថ្នល់នៅកម្ពុជា។

ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុដែលមានស្រាប់នៅកម្ពុជាសម្រាប់ការស្តារវិស័យផ្លូវថ្នល់ពីគ្រោះមហន្តរាយ៖

- **ឧបករណ៍ផ្តល់ហិរញ្ញប្បទានមុនពេលមានហានិភ័យគ្រោះមហន្តរាយ ៖** បង្កើតឡើងទុកជាមុនដោយរដ្ឋាភិបាល និងអាចអនុវត្តបានយ៉ាងឆាប់រហ័ស ក្រោយពេលមានព្រឹត្តិការណ៍គ្រោះមហន្តរាយណាមួយ។
  - **ថវិកាយថាភាព ៖**
    - កម្ពុជាមានថវិកាយថាភាពរួមប្រមាណ ១១៥ លានដុល្លារ ដែលគ្រប់គ្រងដោយទីស្តីការគណៈរដ្ឋមន្ត្រី។ ទោះជាយ៉ាងណាគេប៉ាន់ស្មានថា បច្ចុប្បន្ន ថវិកាតិចជាង ១០% ត្រូវបានលៃទុក និងប្រើប្រាស់សម្រាប់គ្រោះមហន្តរាយក្នុងមួយឆ្នាំៗ។
  - **ឥណទានយថាភាព ៖**
    - បច្ចុប្បន្ន កម្ពុជាមិនមានឥណទានយថាភាពនោះទេ និងប្រើប្រាស់ឥណទានយថាភាពដែលផ្តល់ដោយដៃគូអន្តរជាតិ ដូចជាធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិជប៉ុន សម្រាប់ការស្តារ និងស្តាបនាឡើងវិញពីគ្រោះមហន្តរាយ។
    - ឧបករណ៍ផ្តល់ហិរញ្ញប្បទានក្រោយពេលមានហានិភ័យគ្រោះមហន្តរាយ ៖ ប្រភពដែលត្រូវបានកំណត់ ឬមានក្នុងពេល ឬក្រោយពេលមានគ្រោះមហន្តរាយ។
  - **វិភាជថវិកាឡើងវិញ ៖**
    - គេអាចបែងចែកឡើងវិញនូវថវិកាសម្រាប់ការជួសជុល និងថែទាំ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយ។ វិភាជថវិកាឡើងវិញក្រោយពេលមានគ្រោះមហន្តរាយអាចផ្តល់ថ្លៃឱកាស (opportunity cost) យ៉ាងច្រើនពីចំណាយដែលបានគ្រោងទុកជាមុន និងបង្វែរទិសដៅវឌ្ឍនភាពនៃការសម្រេចបានគោលដៅ និងគោលបំណងអភិវឌ្ឍន៍ជាតិ និងវិស័យ។
  - **ជំនួយពីម្ចាស់ជំនួយ**
    - ម្ចាស់ជំនួយសំខាន់ៗរួមមាន ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងការបរិច្ចាគពីប្រទេសផ្សេងទៀត ដូចជា ជប៉ុន អូស្ត្រាលី និងបណ្តាប្រទេសនៅអឺរ៉ុប។
    - គេអាចសំយោគគម្រោងស្តាបនាវិស័យផ្លូវថ្នល់ឡើងវិញ (គម្រោងដែលមានស្រាប់) ទទួលបានមូលនិធិពីសហគមន៍ម្ចាស់ជំនួយ ជាពិសេសធនាគារអភិវឌ្ឍន៍អាស៊ី[៩] ជាមួយគម្រោងស្តារឡើងវិញពីគ្រោះមហន្តរាយ ឱ្យតែគោលបំណង និងតម្រូវការស៊ីសង្វាក់គ្នា។

## ការសម្របសម្រួល និងការគ្រប់គ្រងមូលនិធិដែលបានបែងចែក

ការបែងចែកមូលនិធិរហ័ស ប៉ុន្តែប្រកបដោយតម្លាភាព ជាកត្តាសំខាន់ក្នុងការបំពេញតម្រូវការស្តារឡើងវិញភ្លាមៗ។ ចំណុចនេះរួមមានការបង្កើតនីតិវិធីចាំបាច់ដែលអាចកាត់បន្ថយពេលវេលាក្នុងការរៀបចំ អនុម័ត និងធ្វើលទ្ធកម្មគម្រោង។

[៩] ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងផ្តល់ជំនួយដល់ការកែលម្អផ្លូវជាតិ តាមរយៈគម្រោងកែលម្អបណ្តាញផ្លូវថ្នល់នៅកម្ពុជា (RNIP) និងផ្លូវជនបទ តាមរយៈគម្រោងកែលម្អផ្លូវជនបទ (RRIP)។

ចំណុចដៅសំខាន់ៗសម្រាប់ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃហិរញ្ញវត្ថុ ៖

- មូលនិធិដែលត្រូវបានបែងចែក និងចំណាយពីគ្រប់ប្រភពទាំងអស់
- វឌ្ឍនភាពនៃការស្តារឡើងវិញ
- ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គម

ការពិនិត្យឡើងវិញលើមូលនិធិដែលត្រូវបានបែងចែក និងវឌ្ឍនភាពនៃការស្តារកំណាត់ផ្លូវផ្សេងៗ អាចកំណត់រកផ្នែកដែលផ្តត់ផ្គង់ជំនួយមូលនិធិលើសតម្រូវការ និងផ្នែកដែលផ្គត់ផ្គង់មូលនិធិទាបជាងតម្រូវការ។

ការពិនិត្យតាមដាន និងវាយតម្លៃមូលនិធិដែលត្រូវបានបែងចែក ជាផ្នែកមួយនៃការពិនិត្យតាមដាន និងវាយតម្លៃជារួមលើការស្តារឡើងវិញពីគ្រោះមហន្តរាយ និងត្រូវបានលើកមកពិភាក្សាជាផ្នែកមួយនៃដំណើរការនេះ ក្រោមផ្នែកអនុវត្តន៍។

### អនុសាសន៍ដើម្បីកែលម្អឧបករណ៍ហិរញ្ញវត្ថុសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយ

បច្ចុប្បន្ន មិនមានការបែងចែកមូលនិធិយថាភាពសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយនោះទេ និងគួរពិភាក្សាចំណុចនេះជាមួយភាគីពាក់ព័ន្ធ។ មូលនិធិយថាភាពអាចច្បាមយកចំណែកតូចមួយនៃជំពូកថវិកាសម្រាប់ការជួសជុលថែទាំ និងកែលម្អជាប្រចាំ ដែលអាចប្រើប្រាស់សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងករណីមិនមានគ្រោះមហន្តរាយ និងកាត់បន្ថយលទ្ធភាពនៃការខ្វះមូលនិធិក្រោយពេលមានគ្រោះមហន្តរាយ ប្រសិនបើប្រើអស់ជំនួយមូលនិធិដែលត្រូវបានបែងចែកសម្រាប់ការជួសជុលថែទាំ និងកែលម្អ មុនការរាំងស្ទះដោយសារគ្រោះមហន្តរាយ។ ការបង្កើត "មូលនិធិគ្រោះមហន្តរាយ" ក៏ជាលក្ខខណ្ឌតម្រូវសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ ២០១៥ ផងដែរ។ ច្បាប់នោះចែងថា "រដ្ឋត្រូវមានថវិកា និងធនធានបម្រុងសមស្របសម្រាប់ធានាការគ្រប់គ្រងគ្រោះមហន្តរាយ" (ជំពូកទី ៧ មាត្រា ៣៩) (ព្រះរាជាណាចក្រកម្ពុជា, ២០១៥)។ នេះជាឱកាសសម្រាប់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការបង្កើតមូលនិធិគ្រោះមហន្តរាយដើម្បីគាំទ្រដល់ការគ្រប់គ្រង និងការស្តារឡើងវិញពីគ្រោះមហន្តរាយ។

ម្ចាស់ជំនួយ និងជំនួយអន្តរជាតិជាប្រភពផ្តល់មូលនិធិចម្បងដល់គ្រោះមហន្តរាយធំៗ ប៉ុន្តែការផ្តល់មូលនិធិមិនមានភាពជាប់លាប់នោះទេ។ ខណៈដែលការពឹងផ្អែកលើជំនួយពីម្ចាស់ជំនួយអាចមិនមានប្រសិទ្ធភាពគ្រប់ពេល គេអាចប្រើប្រាស់មូលនិធិដែលទទួលបានសម្រាប់បំពេញបន្ថែមលើប្រភពមូលនិធិដែលមានស្រាប់ និងវិនិយោគលើ BBB។ គណៈកម្មាធិការហិរញ្ញវត្ថុអាចដាក់សំណើជាអន្តរជាតិ (international appeal) និងធ្វើសន្និសីទម្ចាស់ជំនួយ។ នេះក៏អាចជាប្រភពមូលនិធិដ៏ល្អមួយផងដែរ។ ការប្រើប្រាស់ផែនការស្តារឡើងវិញ និងការបន្សុំផែនការទាំងនេះទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នឹងជួយបង្កើតទឡ្ហីករណ៍រឹងមាំសម្រាប់ការស្នើសុំមូលនិធិ។ គេអាចបែងចែកជំនួយពីម្ចាស់ជំនួយជាជំនួយសង្គ្រោះ និងជំនួយសម្រាប់ការស្តារឡើងវិញ ដោយផ្អែកទៅតាមគោលបំណងរបស់ម្ចាស់ជំនួយ និងកាលប្បវត្តិនៃការទទួលបានមូលនិធិ។

ការបង្កើនពន្ធក៏ជាឧបករណ៍ទូទៅមួយ សម្រាប់ការផ្តល់មូលនិធិដល់តម្រូវការស្តារឡើងវិញរយៈពេលវែងផងដែរ ប៉ុន្តែបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាមិនប្រើប្រាស់ឧបករណ៍នេះឡើយ។ គេអាចបង្កើតទឡ្ហីករណ៍រឹងមាំមួយសម្រាប់ការបង្កើនពន្ធជាមួយសហគមន៍ ប្រសិនបើមូលនិធិត្រូវបានបែងចែកដើម្បីបង្កើនកម្រិតជីវភាពរបស់ពួកគេ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

# នីតិវិធីសម្រាប់ការអនុវត្តការស្តារវិស័យផ្លូវថ្នល់ឡើងវិញ

ដើម្បីដំណើរការការស្តារឡើងវិញពីគ្រោះមហន្តរាយ អ្វីដែលចាំបាច់គឺត្រូវប្រែក្លាយការជំរុញជាយុទ្ធសាស្ត្រ និងអាទិភាពទៅជាគម្រោង និងកម្មវិធីដែលអាចអនុវត្តបាន និងមានការព្រាងផែនការអនុវត្តន៍ សម្រាប់ទ្រទ្រង់ដំណើរការជារួម។ ផែនការអនុវត្តន៍ត្រឹមត្រូវ នឹងត្រួសត្រាយផ្លូវកម្មវិធី និងផែនការឆ្ពោះទៅរកគន្លងប្រក្រតីភាពថ្មីដែលបានគ្រោងទុក។

គួរអនុវត្តតាមជំហានខាងក្រោមក្នុងពេលអនុវត្តការស្តារឡើងវិញ ៖

- បង្កើតស្តង់ដារនៃការស្ថាបនាឡើងវិញ
- កែសម្រួលយុទ្ធសាស្ត្រអនុវត្តន៍ជាប្រចាំឱ្យស្របទៅតាមបរិបទនៃការស្តារឡើងវិញពីគ្រោះមហន្តរាយ
- បង្កើតប្រព័ន្ធបណ្តោះអាសន្ន និងកំណត់អាទិភាពគម្រោងភ្លាមៗ
- ប្រើប្រាស់ប្រព័ន្ធលទ្ធកម្មដែលត្រូវបានកែសម្រួលទៅតាមបរិបទនៃការស្តារឡើងវិញ
- ធានាការសម្របសម្រួលក្នុងជួររដ្ឋាភិបាល និងការអនុវត្តតាមមូលដ្ឋាន
- ធានាការចូលរួមរបស់សហគមន៍
- បង្កើតប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ
- បង្កើតបណ្តាញផ្សព្វផ្សាយ។

## បង្កើតស្តង់ដារនៃការស្ថាបនាឡើងវិញ

ក្នុងបរិបទក្រោយពេលមានគ្រោះមហន្តរាយ គេអាចធ្វើបច្ចុប្បន្នភាពស្តង់ដារនៃការស្ថាបនាឡើងវិញដើម្បីប្រើប្រាស់ព្រឹត្តិការណ៍គ្រោះមហន្តរាយជាឱកាស ការកសាងឡើងវិញឱ្យកាន់តែប្រសើរ និងការធានាបរិយាបន្ន។

អនុវត្តតាមជំហានខាងក្រោមដើម្បីធ្វើបច្ចុប្បន្នភាពស្តង់ដារនៃការស្ថាបនាឡើងវិញ ៖

- ពិនិត្យឡើងវិញលើស្តង់ដារនៃការស្ថាបនាដែលមានស្រាប់ ដោយឱ្យអ្នកជំនាញផ្នែកភាពធន់កំណត់រកគម្លាត
- ធ្វើបច្ចុប្បន្នភាពកត្តាសុវត្ថិភាព និងគោលការណ៍ណែនាំស្តីពីកាប៉ាស៊ីតេផ្លូវ ស្ពាន និងការរចនាលូឱ្យឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងការកើនឡើងនៃតម្រូវការ
- ធ្វើឱ្យមានស្តង់ដារនូវដំណោះស្រាយកាត់បន្ថយផលប៉ះពាល់បែបបៃតង និងមានប្រសិទ្ធភាពចំណាយ ក្នុងការស្ថាបនាឡើងវិញ ដូចជា វត្ថុធាតុធ្វើចិញ្ចើមផ្លូវដែលអាចជ្រាបទឹកបាន របាំងធម្មជាតិការពារឆ្នេរ ( living shoreline )។ល។
- កំណត់ថាតើស្តង់ដារនៃការស្ថាបនាឡើងវិញ រឹតត្បិតនវានុវត្តន៍ និងការអភិវឌ្ឍភាពធន់ ឬទេ រួចធ្វើការផ្លាស់ប្តូរចាំបាច់។

ឧទាហរណ៍នវានុវត្តន៍ក្នុងវិស័យផ្លូវថ្នល់ មានដូចជា វត្ថុធាតុដើមជាជម្រើសសម្រាប់ការស្ថាបនាចិញ្ចើមផ្លូវ ប្រព័ន្ធចិញ្ចើមផ្លូវឆ្លាតវៃ (IFAI Industry News, 2022) ស្ពានបណ្ដែតទឹកនៅវ៉ាស៊ីនតោន (Hess, Pang, & Nelson, 2016) និងផ្លូវក្រោមដីនៅគូឡាឡាំពួដែលនៅពេលថ្ងៃគឺជាផ្លូវហាយវេ ប៉ុន្តែនៅពេលមានការកញ្ជ្រោលនៃខ្យល់ព្យុះគឺជាប្រព័ន្ធបង្ហូរទឹក (Euklidiadas, 2021)។ ប្រអប់ទី ៣ បង្ហាញពីឧទាហរណ៍នៃគម្រោងកាត់បន្ថយផលប៉ះពាល់បែបបៃតង/ធម្មជាតិ ដែលកត់សម្គាល់ដោយអាជ្ញាធរសហព័ន្ធគ្រប់គ្រងគ្រោះអាសន្ន នៅសហរដ្ឋអាមេរិក។

ដោយសារតែស្តង់ដារអតិបរមាបច្ចុប្បន្នដែលបង្កើតឡើងដោយក្រសួងសាធារណការ និងដឹកជញ្ជូន មានបង្ហាញក្នុងគេហទំព័រផ្លូវការតាំងពីឆ្នាំ ២០០១ (MPWT, 2001) គួរមានការធ្វើបច្ចុប្បន្នភាពស្តង់ដារនៃការស្ថាបនាឡើងវិញសម្រាប់គម្រោងកែលម្អផ្លូវថ្នល់ផ្សេងៗ។ ការសិក្សាក្នុងឆ្នាំ ២០០៦ ស្តីពីបណ្ដាញផ្លូវថ្នល់នៅកម្ពុជា បង្ហាញពីគម្រោងកែលម្អផ្លូវថ្នល់ជាច្រើន អមជាមួយនឹងបញ្ហាដែលបានកំណត់ពាក់ព័ន្ធនឹងប្រព័ន្ធផ្លូវថ្នល់ដែលមានស្រាប់ (JICA, 2006)។ ក្នុងឆ្នាំ ២០១១ ការរៀបចំគម្រោងកែលម្អផ្លូវខេត្តដោយធនាគារអភិវឌ្ឍន៍អាស៊ី គូសបញ្ជាក់ពីភាពចាំបាច់នៃការធ្វើបច្ចុប្បន្នភាពស្តង់ដារនៃការស្ថាបនាឡើងវិញសម្រាប់ផ្លូវខេត្ត (KCI, 2011)។ សម្រាប់ផ្លូវជនបទ គម្រោងកែលម្អផ្លូវជនបទដែលអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ក៏បញ្ជាក់ពីភាពចាំបាច់នៃការធ្វើបច្ចុប្បន្នភាពស្តង់ដារនៃការស្ថាបនាឡើងវិញសម្រាប់ផ្លូវជនបទនៅកម្ពុជាផងដែរ (MRD, 2014)។

ក្នុងចំណោមគម្រោងកែលម្អផ្លូវជាតិនៅកម្ពុជា គម្រោងមួយដែលដឹកនាំដោយទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានបង្ហាញពីការប្រៀបធៀបស្តង់ដារនៃការរចនាផ្លូវរបស់កម្ពុជាទៅនឹងស្តង់ដារផ្លូវហាយវេអាស៊ី និងផ្តល់ជាអនុសាសន៍។

**តារាងទី ១ ៖ ស្តង់ដារនៃការរចនាផ្លូវថ្នល់នៅកម្ពុជា ធៀបនឹងស្តង់ដារអាស៊ី និងអនុសាសន៍សម្រាប់ការធ្វើបច្ចុប្បន្នភាពស្តង់ដារនៅកម្ពុជា គិតត្រឹមឆ្នាំ ២០១៤ (JICA, 2014)។**

| ការប្រៀបធៀបល្បឿន និងលក្ខណៈវិនិច្ឆ័យ និងសមាសភាគមុខកាត់ | | | | | |
|---|---|---|---|---|---|
| ស្តង់ដារ | ផ្លូវហាយវេអាស៊ី | ស្តង់ដារកម្ពុជា | | អនុសាសន៍ (ឆ្នាំ២០១៤) | |
| ប្រភេទផ្លូវ | កម្រិតទី I | ជនបទ | ប្រជុំជន | ជនបទ | ប្រជុំជន |
| ល្បឿន | 100 km/h | 100km/h | 50km/h | 100km/h | 50km/h |
| កាំកំណោងអប្បបរមា (Super elevation) | 360 m | 415 m | 90 m | 350 m | 80 m |
| ទទឹងគន្លងផ្លូវ | 3.5 m | 3.5 m | | 3.5 m | |
| ទទឹងស្មា (Shoulder Width) | 3 m | 3 m | 2.5 m | 3 m | |
| Median Strip | 3 m | 4~12 m | 2~4 m | 3 m | |
| Cross Slope | 2% | 2.5~3% | | 2% | |

នៅឆ្នាំ ២០២២ ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងធ្វើការជាមួយសមាគម Austroads ដើម្បីធ្វើបច្ចុប្បន្នភាពស្តង់ដារនៃការរចនាផ្លូវថ្នល់នៅកម្ពុជា (Partnerships for Infrastructure, 2022)។ គួរប្រើប្រាស់ចំណុចទាំងនេះជាស្តង់ដារគោលសម្រាប់ការស្តារឡើងវិញ (លុះត្រាតែមានកំណែថ្មីនៅពេលបង្កើតក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ)។

ក្រៅពីនេះ ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពស្តង់ដារនៃការស្ថាបនាឡើងវិញ គួរពិចារណាដាក់បញ្ចូលបរិយាបន្ន និងសមធម៌ទៅក្នុងការអនុវត្តគម្រោង។ ការបង្កើតស្តង់ដារអប្បបរមាសម្រាប់ការបង្កភាពងាយស្រួលក្នុងតំបន់នីមួយៗដែលមានក្រុមជួបការលំបាក នឹងតម្រែតម្រង់គម្រោងឱ្យផ្តោតគោលដៅលើសហគមន៍ដែលងាយរងគ្រោះបំផុត។

រឹតត្បិតការបាត់បង់ទ្រព្យសម្បត្តិនាពេលអនាគត និងកាត់បន្ថយការបាត់បង់ទ្រព្យសម្បត្តិក្នុងការវិនិយោគ (exposure of assets) តាមរយៈការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធការពារដែលកាន់តែរឹងមាំ ដូចជា ជញ្ជាំងសមុទ្រ និងប្រព័ន្ធបង្ហូរទឹកសមស្រប ដោយប្រើវត្ថុធាតុដើមដែលបង្កើនភាពធន់នៃទ្រព្យសម្បត្តិដឹកជញ្ជូន ឬអនុវត្តដំណោះស្រាយ "ដែលមានភាពទន់ភ្លន់" ឬ "បែបធម្មជាតិ" ដូចជា ការចាក់បន្ថែមល្បាប់នៅតាមឆ្នេរសមុទ្រ ការការពារថ្មប៉ប្រះទឹក និងការអភិរក្សព្រៃកោងកាង (GFDRR, 2018)។

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួននៃការធ្វើឱ្យប្រសើរឡើង ដែលអាចជួយការពារផ្លូវថ្នល់នៅកម្ពុជាទល់នឹងគ្រោះមហន្តរាយនាពេលអនាគត ៖

- លើកខឿនឱ្យដល់កម្រិតខ្ពស់ជាងកម្រិតទឹកជំនន់ដែលអាចជន់លិចកំណាត់ផ្លូវ
- កែលម្អស្រទាប់ដី (subgrade) ដោយប្រើចិញ្ចើមផ្លូវដែលមានស្រាប់ ជាស្រទាប់ដីសម្រាប់ចិញ្ចើមផ្លូវថ្មីដែលគ្រោងឡើង ឬប្រើស៊ីម៉ង់ត៍ដើម្បីរក្សាលំនឹងស្រទាប់ដី។
- កែលម្អប្រព័ន្ធបង្ហូរទឹក អមជាមួយនឹងការកែលម្អផ្លូវ ៖ ត្រូវពង្រីកលូឱ្យសមនឹងទំហំផ្លូវ ក្នុងពេលពង្រីកផ្លូវ។ បង្កើនកាប៉ាស៊ីតេនៃប្រព័ន្ធបង្ហូរទឹកឱ្យឆ្លើយតបទៅនឹងការកើនឡើងបរិមាណទឹកទឹកភ្លៀងដែលបង្ហូរមក ដើម្បីបង្ការទឹកជំនន់។
- ការបន្ថែមឆ្នូត (rumble strip) លើកំណាត់ផ្លូវ ដែលអាចជន់លិចម្តងម្កាល ដើម្បីឱ្យអ្នកបើកបរអាចប៉ាន់ប្រមាណស្ថានភាពផ្លូវបាន ជាពិសេសប្រសិនបើពិបាកមើលឃើញគំនូសសញ្ញាផ្លូវ (road line)។

ឧទាហរណ៍នៃដំណោះស្រាយ "ដែលមានភាពទន់ភ្លន់" ឬ "បែបធម្មជាតិ" ដែលអាចប្រើប្រាស់ជាវិធានការបន្សាំ ក៏ដូចជាវិធានការកាត់បន្ថយផលប៉ះពាល់សម្រាប់ផ្លូវថ្នល់នៅកម្ពុជា រួមមាន ៖

- ចិញ្ចើមផ្លូវដែលអាចជ្រាបទឹកបាន
- រណ្តៅដើមឈើសម្រាប់ស្រូបជំនន់ទឹកភ្លៀង (stormwater tree pit) នៅតាមដងផ្លូវ
- ការរក្សាលំនឹងជម្រាលដោយប្រើជម្រើសបៃតង ដូចជា brush mattresses, live crib walls, fascines, fencing, and staking, log terracing, and vegetated geotextiles។

ដំណោះស្រាយបែបធម្មជាតិទាំងនេះ ត្រូវបានកំណត់យកជាពិសេសសម្រាប់បរិបទកម្ពុជា ក្នុងផ្នែកមួយនៃគម្រោងឆ្នាំ ២០១៦ របស់ ADB ស្តីពីដំណោះស្រាយបែបធម្មជាតិសម្រាប់ការកសាងភាពធន់ក្នុងទីក្រុង និងទីប្រជុំជន ៖ ករណីសិក្សាពីមហាអនុតំបន់ទន្លេមេគង្គ។

ឧទាហរណ៍នៃដំណោះស្រាយបៃតងសម្រាប់ការកាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់ ដែលត្រូវបានអនុវត្តក្នុងប្រទេសនានា មានបង្ហាញក្នុងប្រអប់ទី ៣ (ដំណោះស្រាយកាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់តាមបែបធម្មជាតិ ដែលលើកឡើងដោយ FEMA ដែលជាទីភ្នាក់ងារគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់នៅសហរដ្ឋអាមេរិក)។

## ប្រអប់ទី ៣ ៖ ឧទាហរណ៍នៃគម្រោងកាត់បន្ថយផលប៉ះពាល់ បែងចែកតាមប្រភេទមុខសញ្ញាគ្រោះថ្នាក់ ៖ ការលើកកម្ពស់ការកាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់តាមបែបធម្មជាតិ តាមរយៈឥណទានឥតសំណងរបស់ FEMA សម្រាប់ការកាត់បន្ថយផលប៉ះពាល់

| កម្រិត | មជ្ឈដ្ឋាន | ជំនន់ទឹកទន្លេ ឬ ទីប្រជុំជន | ជំនន់តំបន់ឆ្នេរ | ភ្លើងឆេះព្រៃ |
|---|---|---|---|---|
| ទីជម្រាល ឬ តំបន់ទេសភាព | ប្រជុំជន ↓ ជនបទ | • ច្រករបៀងអភិរក្ស (greenway)<br>• ការកែលម្អលូ<br>• ការបំភ្លឺដោយពន្លឺថ្ងៃ<br>• ការអភិវឌ្ឍដែលបង្កផលប៉ះពាល់តិច<br>• សួនជំនន់ទឹកភ្លៀង (stormwater)<br>• ទ្រនាប់ពាម<br>• ការស្តារស្ទឹង/ទន្លេ<br>• Horizontal setback levee<br>• ការស្តារទំនាបលិចទឹកឡើងវិញ<br>• ការលុបបំបាត់ទំនប់<br>• ការអភិរក្សដី | • ការកែលម្អលូ<br>• សួនប្របមាត់ទឹក<br>• សួនតាមឆ្នេរ *<br>• Tidal circulation<br>• របាំងធម្មជាតិការពារឆ្នេរ (living shoreline)<br>• ការស្តារបណ្តាញផ្លូវទឹក<br>• ឆ្នេរខ្សាច់ និងពំនូកខ្សាច់<br>• ការស្តារថ្មប៉ប្រះទឹក<br>• ការស្តារតំបន់ដីសើមតំបន់ឆ្នេរ (វាលភក់ និងកោងកាង)<br>• ការអភិរក្សដី | • ការសម្អាតកំទេចកំទីពីទីប្រជុំជនក្រោយពេលមានគ្រោះអគ្គិភ័យ<br>• ការយកចេញដើមឈើដែលអាចបង្កគ្រោះថ្នាក់ក្រោយពេលមានគ្រោះអគ្គិភ័យ<br>• ការគ្រប់គ្រងសារពើរុក្ខជាតិ<br>• ការកាត់ដើមឈើចោលមួយចំនួន (forest thinning)<br>• ការដាំព្រៃឡើងវិញ<br>• ពិពិធកម្មព្រៃឈើ |
| តំបន់ក្បែរខាង/ការដ្ឋាន | ប្រជុំជន ↓ ជនបទ | • ដំបូលបៃតង<br>• វិថីបៃតង<br>• ចិញ្ចើមផ្លូវដែលអាចជ្រាបទឹកបាន<br>• សួនទឹកភ្លៀង<br>• កាណូភីដើមឈើ (tree canopy)<br>• ការត្រងទឹកភ្លៀង<br>• លទ្ធកម្មដីធ្លី | • ការកែលម្អលូ<br>• សួនប្របមាត់ទឹក<br>• តំបន់ដីសើមសម្រាប់ត្រងជំនន់ទឹកភ្លៀង<br>• របាំងធម្មជាតិការពារឆ្នេរ<br>• ការស្តារតំបន់ដីសើមតាមមាត់ឆ្នេរ<br>• ការស្តារថ្មប៉ប្រះទឹក (shellfish reef) | • ដំបូលដែលធន់នឹងចំហេះ និងអគ្គិភ័យ<br>• ការបំពាក់បន្ថែមនូវសម្ភារសាងសង់ដែលធន់នឹងចំហេះ<br>• ការបង្កើតតំបន់ទេសភាពដែលធន់នឹងអគ្គិភ័យ<br>• ការតម្រូវឱ្យកាត់ចេញ ដើម្បីកាត់បន្ថយបរិមាណឥន្ទនៈ<br>• ការរក្សាលំនឹងដីក្រោយពេលមានគ្រោះអគ្គិភ័យ<br>• ការបង្កើតចន្លោះទំនេរដែលអាចការពារបាន |

## កែសម្រួលយុទ្ធសាស្ត្រអនុវត្តន៍ដែលមានស្រាប់ ឱ្យស្របទៅនឹងបរិបទនៃការស្តារឡើងវិញ

ដោយសារត្រូវបំពេញតម្រូវការស្តារឡើងវិញក្រោមចិរវេលាខ្លី ការអនុវត្តកម្មវិធី និងគម្រោងឱ្យបានជាប់លាប់នៅក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ប្រហែលមិនមែនជាប្រព័ន្ធសមស្របនោះទេ ហើយក្រោមភាពបន្ទាន់ការបង្កើតប្រព័ន្ធអនុវត្តថ្មីមួយ ក៏មិនមែនជាជម្រើសដែលមានប្រសិទ្ធភាពបំផុតផងដែរ។ ដូច្នេះ ចាំបាច់ត្រូវមានអភិក្រមចម្រុះមួយក្នុងករណីមានការកែសម្រួលប្រព័ន្ធមានស្រាប់សម្រាប់ការអនុវត្តកម្មវិធីវិស័យផ្លូវថ្នល់ ឱ្យស្របទៅតាមចិរវេលាលឿនក្នុងបរិបទនៃការស្តារឡើងវិញ។

ខាងក្រោមនេះជាផ្នែកនៃការអនុវត្តដែលចាំបាច់ត្រូវកែសម្រួលឱ្យស្របទៅតាមបរិបទនៃការស្តារឡើងវិញ៖

- ការកំណត់អាទិភាពគម្រោង ៖ កំណត់អាទិភាពទៅតាមតម្រូវការស្តារឡើងវិញ និងភាពពាក់ព័ន្ធនៃទ្រព្យសម្បត្តិទៅនឹងកំណើនរបស់ប្រទេស
- ការបង្កើតប្រព័ន្ធបណ្តោះអាសន្ន ៖ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងសង្គ្រោះបន្ទាន់ (ការចែកចាយស្បៀងអាហារ និងសេវាវេជ្ជសាស្ត្រ។ល។) និងគ្រប់គ្រងចរាចរណ៍ក្នុងពេលស្តាបនាហេដ្ឋារចនាសម្ព័ន្ធឡើងវិញ
- ការបង្កើតយុទ្ធសាស្ត្រចាកចេញសម្រាប់ប្រព័ន្ធបណ្តោះអាសន្ន
- ការបង្កើតដំណើរការលទ្ធកម្មដែលឆាប់រហ័សជាងមុន
- ការសម្របសម្រួល និងទំនាក់ទំនងតាមខ្សែបញ្ឈរ និងតាមខ្សែផ្តេករវាងនាយកដ្ឋានរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ស្ថាប័នដឹកនាំវិស័យហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ និងម្ចាស់ជំនួយខាងក្រៅ។

ក្រៅពីនេះ ផែនការអនុវត្តន៍ត្រូវពិចារណាពីភាពប្រទាក់ក្រឡាគ្នារវាងគម្រោងនានា ក្នុងករណីដែលការជួសជុលកំណាត់ផ្លូវមួយអាចបង្វែរចរាចរណ៍ទៅផ្លូវមួយផ្សេងទៀត ដែលប្រហែលជាមិនអាចទ្រទ្រង់លំហូរចរាចរណ៍ដ៏មមាញឹកបាន។ ការគូសផែនទីគម្រោង និងការត្រាប់តាមការផ្លាស់ប្តូរនៃគំរូចរាចរណ៍ អមជាមួយនឹងភាពងាយរងគ្រោះនៃទ្រព្យសម្បត្តិ អាចរំលេចភាពប្រទាក់ក្រឡាគ្នានៃគម្រោងនេះ ដោយបញ្ចៀសផលវិបាកចៃដន្យដោយសារគម្រោង។

ក្រុមជួយពិនិត្យឯកសារពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូន (transport peer review panel) រួមទាំងអ្នកអនុវត្តន៍ក្នុងវិស័យដឹកជញ្ជូន និងស្ថាប័នសិក្សាស្រាវជ្រាវ នឹងជួយដល់ការវាយតម្លៃទាំងនេះ។

ក្នុងដំណាក់កាលអនុវត្តការស្តារឡើងវិញ អ្វីដែលសំខាន់ផងដែរនោះគឺត្រូវបង្កើតដំណើរការប្រតិបត្តិការ និងជួសជុលថែទាំជាប្រចាំក្រោយពេលស្តារឡើងវិញ។ ការបង្កើតយុទ្ធសាស្ត្រគ្រប់គ្រង និងដំណើរការប្រព័ន្ធដឹកជញ្ជូន (TSMO) ដែលមានភាពសមស្រប ជាប្រការសំខាន់សម្រាប់ការធានាថា វឌ្ឍនភាពក្នុងដំណើរការស្តារឡើងវិញតាមរយៈការដាក់បញ្ចូល BBB មិនត្រូវបានរាំងស្ទះដោយសារកង្វះការថែទាំប្រព័ន្ធទាំងនេះឱ្យបានសមស្រប។

## បង្កើតប្រព័ន្ធបណ្តោះអាសន្ន និងកំណត់អាទិភាពគម្រោងផ្សេងៗ

មន្ត្រីផ្នែកដឹកជញ្ជូន ត្រូវពិចារណាពីរបៀបគ្រប់គ្រងចរាចរណ៍ប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងដំណាក់កាលស្តារឡើងវិញ និងបង្កើតសេវាបណ្តោះអាសន្នដើម្បីជំនួសឱ្យសេវាដែលត្រូវបានបង្អាក់ក្នុងរយៈពេលខ្លី ដើម្បីកាត់បន្ថយផលប៉ះពាល់ផ្នែក

សេដ្ឋកិច្ច។ ចំណុចនេះរួមមាន ៖

- ការរៀបចំផ្លូវវាង (FHWA, 2013)
- ប្រព័ន្ធព័ត៌មានចាំបាច់ដើម្បីផ្តល់ព័ត៌មានលម្អិតស្តីពីផ្លូវវាងដល់សាធារណជន
- ស្ពានបណ្តោះអាសន្នសម្រាប់ការជម្លៀស និងការស្តារចរាចរណ៍ឡើងវិញ (Savani, 2016)។

ការវាស់ស្ទង់ចរាចរណ៍ និងការវិភាគហានិភ័យកម្រិតទ្រព្យសម្បត្តិ ដែលបានធ្វើឡើងមុនពេលមានគ្រោះមហន្តរាយ នឹងជួយដល់ការអភិវឌ្ឍប្រព័ន្ធបណ្តោះអាសន្នទាំងនេះ។ អ្វីដែលសំខាន់ផងដែរនោះគឺនៅដំណាក់កាលនេះ គេត្រូវបង្កើតយុទ្ធសាស្រ្តចាកចេញ និងកំណត់ចិរវេលានៃប្រព័ន្ធបណ្តោះអាសន្នទាំងនេះ។

ការសម្អាតកំទេចកំទី និងការវាយកម្ទេច ជាសកម្មភាពចាំបាច់មួយដែលត្រូវធ្វើឡើង ដើម្បីសម្រួលដល់ការស្តារឡើងវិញ។ វាជាការសំខាន់ក្នុងការសម្អាតកំទេចកំទី និងកំណត់ហេដ្ឋារចនាសម្ព័ន្ធ (រួមទាំងអគារដែលទ្រទ្រង់ដល់ការដឹកជញ្ជូន) ដែលអាចនឹងត្រូវកម្ទេចចោល ដោយសារលែងអាចជួសជុលបាន ឬលែងត្រូវការ ឬមានទីតាំងស្ថិតក្នុងតំបន់មុខសញ្ញាគ្រោះថ្នាក់។

## បង្កើតប្រព័ន្ធលទ្ធកម្ម ដែលត្រូវបានកែសម្រួលទៅតាមបរិបទនៃការស្តារឡើងវិញ

កិច្ចលទ្ធកម្មបុគ្គលិក និងគ្រឿងចក្រដើម្បីសម្អាតកំទេចកំទី ជួសជុលផ្លូវ និងស្ពាន ជួសជុលហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗជាបណ្តោះអាសន្ន។ល។ ទាមទារចំណេះដឹងបច្ចេកទេស ពេលវេលា និងធនធានមនុស្ស។ ទន្ទឹមនឹងការធានាថា ដំណើរការនេះបន្សុីគ្នានឹងគោលបំណងនៃការកសាងឡើងវិញឱ្យកាន់តែប្រសើរ ចាំបាច់ត្រូវបញ្ចប់ដំណើរការនេះទៅតាមចិរវេលាកំណត់នៃការស្តារឡើងវិញពីគ្រោះមហន្តរាយ។ ខាងក្រោមនេះជាជំហានដែលគួរអនុវត្តដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីសម្រួលដល់ដំណើរការលទ្ធកម្មយ៉ាងរលូន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ៖

- ធ្វើឱ្យដំណើរការលទ្ធកម្មនៃការជួលអ្នកទទួលការសាងសង់ក្រោមកិច្ចសន្យាមានស្រាប់នៅក្នុងតំបន់ មានលក្ខណៈសាមញ្ញ ដើម្បីសម្រួលដល់ការកៀរគរធនធានដែលមានស្រាប់សម្រាប់ការស្តាបនាឡើងវិញ។
- បង្កើតទម្រង់កិច្ចសន្យាដែលមានលក្ខណៈសាមញ្ញ ដូចជា កិច្ចសន្យាមានចិរវេលាកំណត់ និងកិច្ចសន្យា reimbursable cost-plus fee (ថ្លៃដើមដែលអាចសងវិញបានបូកនឹងថ្លៃសេវា) នៅពេលមិនទាន់បានរៀបចំការរចនា។
- ក្រសួងទាំងពីរអាចកំណត់ជ្រើសរើសអ្នកទទួលការសាងសង់ដែលមានលក្ខណៈសម្បត្តិទុកជាមុន និងបង្កើតជាស្រេចនូវកិច្ចព្រមព្រៀងក្របខ័ណ្ឌជាមួយអ្នកទទួលការសាងសង់ក្នុងមូលដ្ឋាន ដើម្បីកាត់បន្ថយរយៈពេលនៃកិច្ចលទ្ធកម្ម ក្រោយពេលមានគ្រោះមហន្តរាយ។

## ធានាការសម្របសម្រួលរដ្ឋាភិបាល និងគាំទ្រការអនុវត្តក្នុងមូលដ្ឋាន

ស្ថាប័នដឹកនាំការស្តារឡើងវិញ (ពោលគឺក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ) មានតួនាទីបង្កើត និងត្រួតពិនិត្យយន្តការសម្របសម្រួលចាប់ពីថ្នាក់ជាតិ (គ.ជ.គ.ម និងរាជរដ្ឋាភិបាលកម្ពុជា) រហូតដល់ប្រព័ន្ធតាមមូលដ្ឋាន ដែលអនុវត្តគម្រោងទាំងនេះ។

ការសម្របសម្រួលត្រូវធ្វើឡើងតាមខ្សែបញ្ឈរ ដូចជា រវាងថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន និងតាមខ្សែផ្ដេក ដូចជា រវាងអង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងអង្គការសង្គមស៊ីវិល។ ដំណើរការសម្របសម្រួលដោយក្រសួងសាធារណការ និងដឹកជញ្ជូន ពាក់ព័ន្ធនឹងការចាត់តាំងឱ្យទីភ្នាក់ងាររដ្ឋាភិបាល ឬទីភ្នាក់ងារមិនមែនរដ្ឋាភិបាលទទួលបន្ទុកផ្នែកផ្សេងៗនៃការស្ដារឡើងវិញដោយផ្អែកទៅតាមឯកទេសរបស់ពួកគេ។ គេអាចបង្កើតយន្តការសម្របសម្រួលផ្សេងៗ (GFDRR, 2020) ដូចខាងក្រោម ៖

- **ក្រុមការងារសម្របសម្រួលការស្ដារវិស័យដឹកជញ្ជូនឡើងវិញ** ៖ ក្រុមការងារដែលត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងដំណើរការ PDNA និង DRF នេះ មានតួនាទីធានាការសម្របសម្រួលផ្ទៃក្នុងរវាងស្ថាប័ននានា ៖ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ គ.ជ.គ.ម និងមន្ទីរសាធារណការ និងដឹកជញ្ជូន។ ផ្នែកនានា ដូចជា ការរៀបចំកិច្ចសន្យា ដំណើរការដេញថ្លៃ និងលទ្ធកម្ម ការអនុម័តការរចនា និងការគ្រប់គ្រងគុណភាពសម្ភារៈ ត្រូវមានភាពស៊ីសង្វាក់គ្នានៅគ្រប់នាយកដ្ឋានផ្ទៃក្នុងទាំងអស់។

- **ក្រុមការងារ/គណៈកម្មាធិការដែលទទួលបានសិទ្ធិអំណាច** ៖ ក្រុមការងារនេះ (ដែលមានសមាសភាគអ្នកនយោបាយជាន់ខ្ពស់ អ្នកគ្រប់គ្រង និងអ្នកជំនាញ) អាចត្រូវបានបង្កើតឡើងនៅកម្រិតខ្ពស់ក្នុងជួររដ្ឋាភិបាលដើម្បីបង្កើតគោលនយោបាយ/កម្មវិធីស្ដារឡើងវិញ។ ក្រុមការងារនេះអាចរួមបញ្ចូលមន្ត្រីមកពី គ.ជ.គ.ម ដែលធ្លាប់មានបទពិសោធន៍ផ្នែកស្ដារឡើងវិញ អ្នកជំនាញអន្តរជាតិមកពីធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការ UNDP និងអ្នកដឹកនាំនយោបាយ ដែលអាចគាំទ្រដល់ដំណើរការនេះក្នុងប្រព័ន្ធស្ថាប័ន។ យន្តការនេះនឹងលុបបំបាត់គម្លាតជំនាញបច្ចេកទេស ក្នុងករណីចាំបាច់ ដោយមានការជ្រោមជ្រែងពីធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការ UNDP និងធានាការជំរុញផ្នែកស្ថាប័នជាបន្តបន្ទាប់ដើម្បីបញ្ចប់គម្រោងកែលម្អផ្លូវថ្នល់នៅដំណាក់កាលក្រោយៗទៀតនៃការស្ដារឡើងវិញ។

- **គណៈកម្មាធិការសម្របសម្រួលអង្គការមិនមែនរដ្ឋាភិបាល** ៖ អង្គការមិនមែនរដ្ឋាភិបាលអាចដើរតួនាទីសំខាន់ក្នុងការច្បាមយកធាតុចូលពីសហគមន៍ស្ដីពីការស្ដារបណ្ដាញផ្លូវថ្នល់ឡើងវិញ ដោយធានាការបែងចែកកិច្ចខិតខំប្រឹងប្រែងស្ដារឡើងវិញប្រកបដោយសមធម៌ដល់សហគមន៍ទាំងអស់។ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ អាចបង្កើតគណៈកម្មាធិការមួយនៅថ្នាក់ក្រោមជាតិដើម្បីជំរុញការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកម្មវិធីស្ដារឡើងវិញ។ គណៈកម្មាធិការនេះនឹងផ្ដល់ការគាំទ្រ និងសមត្ថកិច្ចចាំបាច់ដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងការអនុវត្តលំហាត់ជំរុញការចូលរួមរបស់សហគមន៍ ជាមួយគណៈកម្មាធិការគ្រប់គ្រងគម្រោងនៅកម្រិតមូលដ្ឋាន។

- **គណៈកម្មាធិការគ្រប់គ្រងគម្រោងនៅកម្រិតមូលដ្ឋាន** ៖ គណៈកម្មាធិការនេះអាចមានសមាសភាគមន្ត្រីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងតំណាងសហគមន៍រងផលប៉ះពាល់។ មន្ត្រីរដ្ឋាភិបាលដែលចូលរួមក្នុងគណៈកម្មាធិការនេះ (មន្ត្រីមកពីមន្ទីរ និងការិយាល័យសាធារណការ និងដឹកជញ្ជូន) អាចផ្សព្វផ្សាយពីថិរវេលាកំណត់ និងធានាតម្លាភាពក្នុងដំណើរការស្ដារផ្លូវថ្នល់ឡើងវិញ ជាមួយសហគមន៍ ខណៈដែលអង្គការមិនមែនរដ្ឋាភិបាល និងអ្នកដឹកនាំសហគមន៍អាចធ្វើជាភ្នែកច្រមុះរបស់សាធារណជនក្នុងការតម្រែតម្រង់ការស្ដារឡើងវិញឱ្យបាញ់ឆ្ពោះទៅរកសហគមន៍ដែលខ្វះខាតបំផុត ដូចជា លទ្ធភាពទទួលបានសេវាសុខាភិបាល ជម្រកក្នុងមូលដ្ឋាន ធនាគារស្បៀង និងហេដ្ឋារចនាសម្ព័ន្ធបណ្ដោះអាសន្នផ្សេងទៀតដែលត្រូវផ្ដោតអាទិភាព។ ព័ត៌មានទាំងនេះអាចទទួលបានពីអង្គការមិនមែនរដ្ឋាភិបាល និងអ្នកដឹកនាំសហគមន៍។

ក្រុមស្ដារឡើងវិញត្រូវប្រមែប្រមូលព័ត៌មានទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធ ដែលអាចជួយដល់ដំណើរការអនុវត្ត មុនពេលចាប់ផ្ដើមគម្រោង។ ភាគីដែលអាចជាដៃគូគ្រប់គ្រងគ្រោះមហន្តរាយ ដែលអាចចូលរួមក្នុងយន្តការសម្របសម្រួលទាំងនេះ មានបង្ហាញក្នុងប្រអប់ទី ៤។

## ប្រអប់ទី ៤ ៖ ដៃគូមកពីវិស័យសង្គមសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយនៅកម្ពុជា

អង្គការភាពជាដៃគូដើម្បីការអភិវឌ្ឍនៅកម្ពុជា (PADEK) ជាអង្គការមិនមែនរដ្ឋាភិបាលមួយនៅកម្ពុជាដែលធ្វើការជាមួយសហគមន៍ក្រីក្រនៅជនបទ ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ពួកគេ។ អង្គការនេះអាចជួយទ្រទ្រង់បរិយាបន្នក្នុងការអនុវត្តការស្តារវិស័យផ្លូវថ្នល់ឡើងវិញ តាមរយៈការកំណត់តំបន់ដែលត្រូវផ្តោតអាទិភាពសម្រាប់ការផ្តល់លទ្ធភាពទទួលបានទំនិញ សេវា និងការងារដល់ប្រជាជនដែលជួបការលំបាក។

សម្ព័ន្ធសហគ្រាសធុនតូច និងមធ្យមកម្ពុជា (FASMEC) ជាបណ្តាញវិស័យឯកជនសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។ ការចូលរួមរបស់សម្ព័ន្ធនេះក្នុងការអនុវត្តការស្តារវិស័យផ្លូវថ្នល់ឡើងវិញនៅកម្រិតមូលដ្ឋាន នឹងធានាថា ការស្តារឡើងវិញបន្សុីគ្នានឹងការទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ដើម្បីឱ្យសហគ្រាសទាំងនោះបង្ហាញវត្តមានជាថ្មីនៅក្នុងទីផ្សារ តាមរយៈការផ្តល់លទ្ធភាពឱ្យសហគ្រាសទាំងនេះចូលដល់សាធារណជន។

ក្រុមធ្វើសកម្មភាពរួម (JAG) ជាក្រុមក្រៅផ្លូវការនៃអង្គការសង្គមស៊ីវិលដែលធ្វើការលើផ្នែកកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា។ ក្រុមនេះរួមបញ្ចូលតំណាងមកពីអង្គការនានា និងអាចប្រើប្រាស់ជាបណ្តាញសម្រាប់ការចូលដល់សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ និងការសម្របសម្រួលជាមួយមន្ត្រីរដ្ឋាភិបាល។

វេទិកាឆ្លើយតបមនុស្សធម៌ (HRF) ជានាការសម្របសម្រួល និងការផ្សព្វផ្សាយគ្រប់ជ្រុងជ្រោយស្តីពីការត្រៀមខ្លួនឆ្លើយតបនឹងគ្រោះអាសន្ន និងការឆ្លើយតបផ្នែកមនុស្សធម៌នៅកម្ពុជា រវាងអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការអន្តរជាតិ។ HRF សហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល ជាពិសេស គ.ជ.គ.ម ដើម្បីធានានូវអភិក្រមដែលមានប្រសិទ្ធភាព និងការសម្របសម្រួល សម្រាប់ជួយដល់ប្រជាជនដែលរងផលប៉ះពាល់ដោយសារវិបត្តិមនុស្សធម៌។

វេទិកាមនុស្សធម៌កម្ពុជា (CHF) ទទួលបានជំនួយមូលនិធិពី USAID/OFDA និងចាប់ផ្តើមឡើងនៅខែ ឧសភា ឆ្នាំ ២០១២។ គម្រោងនេះត្រូវបានសម្របសម្រួលដោយមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) ជាមួយនឹងដៃគូក្នុងប្រទេស (គ.ជ.គ.ម និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ) ក្នុងគោលបំណងបង្កើនការឆ្លើយតបផ្នែកមនុស្សធម៌ទៅនឹងគ្រោះមហន្តរាយនៅកម្ពុជា តាមរយៈការពង្រឹងសមត្ថភាពដឹកនាំរបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីចូលរួមកាន់តែប្រសើរក្នុងក្របខ័ណ្ឌមនុស្សធម៌ តាមរយៈការផ្តល់ធនធានចំណេះដឹង ការបណ្តុះបណ្តាល និងការណែនាំ។

# ធានាការចូលរួមរបស់សហគមន៍

សហគមន៍មិនត្រឹមតែជាក្រុមដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយសារគ្រោះមហន្តរាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាធនធានដ៏សំខាន់ក្នុងដំណើរការស្តារឡើងវិញទៀតផង ប្រសិនបើត្រូវបានជំរុញឱ្យចូលរួមបានត្រឹមត្រូវដោយស្ថាប័នដឹកនាំការស្តារឡើងវិញ។ ធាតុចូលរបស់សហគមន៍ និងការពិនិត្យឡើងវិញលើផែនការ និងគម្រោងស្តារឡើងវិញ អាចជួយរំលេចបញ្ហាប្រឈមក្នុងការអនុវត្ត វិសមភាពគួរឱ្យកត់សម្គាល់ដែលក្រុមស្តារឡើងវិញអាចមើលរំលង និងវិធីលើកកម្ពស់គម្រោង ដោយប្រើជំនាញ និងចំណេះដឹងមូលដ្ឋានរបស់សហគមន៍ទាំងនោះ។

ជំហានសម្រាប់ធានាការចូលរួមរបស់សហគមន៍ ៖

- ចាត់តាំងឱ្យអង្គការមិនមែនរដ្ឋាភិបាល ឬគណៈកម្មាធិការសម្របសម្រួលអង្គការមិនមែនរដ្ឋាភិបាល (ប្រសិនបើមាន) ទទួលខុសត្រូវលើការជំរុញការចូលរួមរបស់សហគមន៍
- រៀបចំកិច្ចប្រជុំសហគមន៍ដើម្បីកំណត់រកចំណុចរសើប (ឧ. ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដែលសហគមន៍មិនអាចទទួលបានមធ្យោបាយដឹកជញ្ជូនដែលត្រូវការចាំបាច់ និងមិនមាន។ល។)
- ធានាការចូលរួមរបស់ក្រុមជួបការលំបាក ដូចជា ស្ត្រី ចាស់ជរា ជនពិការ និងក្រុមវណ្ណៈសង្គមមួយចំនួន ដើម្បីកំណត់ និងបំពេញតម្រូវការផ្នែកលទ្ធភាពទទួលបាន របស់ពួកគេ
- បញ្ចូលសហគមន៍ក្នុងការស្ដារឡើងវិញ តាមរយៈការផ្ដល់ឱកាសការងារបណ្ដោះអាសន្ន ប្រសិនបើអាច។

ផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ចដោយសារការបន្តអនុវត្តការងារស្ថាបនាផ្លូវ ផ្លូវវាង និងការអូសបន្លាយពេលជួសជុលអាចបន្ថែមចំណាយផ្នែកសេដ្ឋកិច្ច (រយៈពេលធ្វើដំណើរ។ល។) និងចំណាយផ្នែកសង្គម (បង្កើនភាពតានតឹង និងភាពតប់ប្រមល់)។ ការជំរុញការចូលរួមរបស់សហគមន៍រងផលប៉ះពាល់ក្នុងដំណើរការស្ដារឡើងវិញ នឹងធ្វើឱ្យពួកគេមានអារម្មណ៍ម្ចាស់ការ និងមានទំនុកចិត្តខ្ពស់លើប្រព័ន្ធនេះ។

## បង្កើតប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ

ក្នុងការស្ដារឡើងវិញពីគ្រោះមហន្តរាយ យើងត្រូវការក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃដើម្បីធានាថា ការអនុវត្តកម្មវិធីឆ្លងកាត់ការវាយតម្លៃដើម្បីវាស់វែងប្រសិទ្ធភាពរបស់វា។ តាមរយៈការបង្កើនគុណភាពនៃការវាយតម្លៃ គេនឹងអាចធ្វើការកែលម្អលើកម្មវិធីស្ដារឡើងវិញពីគ្រោះមហន្តរាយក្រោយៗទៀតបាន។ ការរៀនសូត្រដែលយើងទទួលបានពីការវាយតម្លៃទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងការរចនា និងការអនុវត្តកម្មវិធី។

ការបង្កើតប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ពាក់ព័ន្ធនឹងការកំណត់អ្វីដែលត្រូវពិនិត្យតាមដាន និងវាយតម្លៃ (សកម្មភាព និងលទ្ធផលចុងក្រោយ) ពេលដែលត្រូវពិនិត្យតាមដាន និងវាយតម្លៃ (ចិរវេលា និងភាពញឹកញាប់) របៀបក្នុងការពិនិត្យតាមដាន និងវាយតម្លៃ (ឧបករណ៍ និងសូចនាករ) អ្នកដែលត្រូវធ្វើការពិនិត្យតាមដាន និងវាយតម្លៃ និងរបៀបប្រើប្រាស់លទ្ធផល។

ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដែលមានប្រសិទ្ធភាពសម្រាប់ការស្ដារឡើងវិញ គួរតែអាច ៖

- តាមដានវឌ្ឍនភាពជាក់ស្ដែងនៃសកម្មភាពស្ថាបនាឡើងវិញ
- តាមដានលទ្ធផលសម្រាប់សកម្មភាពស្ដារឡើងវិញផ្សេងទៀត ដែលស្ថិតនៅក្រៅវិសាលភាពនៃការស្ថាបនាឡើងវិញ
- ផ្ដល់ព័ត៌មានជាប់លាប់ និងគ្រប់ជ្រុងជ្រោយស្ដីពីការបែងចែក និងការចាត់ចែងមូលនិធិ (សាធារណៈ និងឯកជន)
- ផ្ដល់ទិន្នន័យសម្រាប់ការវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ច និងសង្គមដោយសារកម្មវិធីស្ដារឡើងវិញ
- ផ្ដល់មូលដ្ឋានព័ត៌មានដល់ការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិ ដោយផ្អែកលើលទ្ធផលចុងក្រោយ លើការអនុវត្តការស្ដារឡើងវិញ។

អនុវត្តជំហានខាងក្រោមដើម្បីបង្កើតប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ការស្ដារវិស័យផ្លូវថ្នល់ឡើងវិញ ៖

- ស្នើឱ្យស្ថាប័នដឹកនាំគម្រោងកំណត់លទ្ធផលរំពឹងទុក និងចិរវេលាសម្រាប់គម្រោងស្ដារឡើងវិញទាំងអស់

- បង្កើតសូចនាករកំណត់ភាពជោគជ័យ ៖ លទ្ធភាពទទួលបាន និងចល័តភាពរបស់សាធារណជន
- កំណត់ចិរវេលាសម្រាប់ការពិនិត្យវឌ្ឍនភាព ដោយផ្អែកលើ % នៃការបញ្ចប់គម្រោង។ សម្រាប់គម្រោងដែលមានរយៈពេលលើស ១ ឆ្នាំ ការពិនិត្យឡើងវិញអាចធ្វើឡើងរៀងរាល់ត្រីមាស។
- កំណត់រក និងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) សម្រាប់ប្រមូល និងរក្សាទុកព័ត៌មានពិនិត្យតាមដាន និងវាយតម្លៃ
- តម្រូវឱ្យដាក់របាយការណ៍វឌ្ឍនភាពជាប្រចាំ ដោយផ្អែកតាមចិរវេលានៃការពិនិត្យឡើងវិញដែលកំណត់ដោយអ្នកទទួលការសាងសង់ និងអ្នកផ្គត់ផ្គង់សេវា ដែលអនុវត្តសកម្មភាពគម្រោង
- ប្រសិនបើអាច ផ្សព្វផ្សាយរបាយការណ៍ទាំងនេះដល់សាធារណជន ដើម្បីកសាងទំនុកចិត្តជាមួយសហគមន៍។

ឧទាហរណ៍មួយនៃការប្រើប្រាស់ការពិនិត្យតាមដាន និងវាយតម្លៃដោយជោគជ័យក្នុងដំណើរការស្តារឡើងវិញពីគ្រោះមហន្តរាយ មានបង្ហាញក្នុងគម្រោងស្ថាបនា និងស្តារឡើងវិញនូវការតាំងទីលំនៅក្នុងសហគមន៍ (CBSRRP) នៅ Yogyakarta ដូចមានបង្ហាញក្នុងប្រអប់ទី ៥ (Katich)។

**ប្រអប់ទី ៥ ៖ ករណីសិក្សាស្តីពីការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់គម្រោងស្ថាបនា និងស្តារឡើងវិញនូវការតាំងទីលំនៅក្នុងសហគមន៍ (CBSRRP) នៅ Yogyakarta**

ក្រោយគ្រោះរញ្ជួយដីឆ្នាំ ២០០៦ នៅ Yogyakarta ប្រទេសឥណ្ឌូនេស៊ី រដ្ឋាភិបាលបានជំរុញកិច្ចខិតខំប្រឹងប្រែងស្តារ និងស្ថាបនាឡើងវិញតាមរយៈការបង្កើតស្តង់ដារ និងការសម្របសម្រួលអន្តរទីភ្នាក់ងារ។ ការពិនិត្យតាមដាន និងវាយតម្លៃត្រូវបានធ្វើឡើងនៅកម្រិតភូមិ និងកម្រិតកម្មវិធី ដោយប្រើអ្នកសម្របសម្រួល និងទម្រង់អេឡិចត្រូនិកសម្រាប់ដំណើរការទាំងមូល។ កិច្ចការនេះធ្វើឱ្យមានការពេញចិត្ត ៩០% ក្នុងចំណោមអ្នកទទួលផល។

សំណាកសូចនាករ DRM ក្រោយពេលមានគ្រោះមហន្តរាយដែលត្រូវបានវាយតម្លៃដោយប្រើប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃសម្រាប់គម្រោងស្ថាបនា និងស្តារឡើងវិញនូវការតាំងទីលំនៅក្នុងសហគមន៍ (CBsrrP) នៅ Yogyakarta

សូចនាករលទ្ធផលចុងក្រោយសំខាន់ៗ

- យ៉ាងហោចណាស់ ផ្ទះសម្បែងចំនួន ៨០% មានអ្នកចូលមករស់នៅ នៅពេលបញ្ចប់គម្រោង
- អ្នកទទួលផល (ទាំងពីរភេទ) លើកឡើងពីការពេញចិត្តផ្ទះសម្បែងដែលត្រូវបានស្ថាបនាឡើងវិញ
- អ្នកទទួលផល (ទាំងពីរភេទ) លើកឡើងពីការពេញចិត្តហេដ្ឋារចនាសម្ព័ន្ធសហគមន៍

**សូចនាករលទ្ធផលរំពឹងទុក**

- ចំនួនផ្ទះសម្បែងដែលបញ្ចប់ការស្ថាបនាឡើងវិញ បំពេញស្តង់ដារបង្ករនៃភាពធន់នឹងការរញ្ជួយដី
- ចំនួនគ្រួសារដែលរស់នៅក្នុងផ្ទះសម្បែងអចិន្ត្រៃយ៍ដែលត្រូវបានសាងសង់ក្នុងសហគមន៍ និងធន់នឹងការរញ្ជួយដី
- ភាគរយនៃភូមិគោលដៅដែលបានស្តារហេដ្ឋារចនាសម្ព័ន្ធសហគមន៍មូលដ្ឋានឡើងវិញ

**សូចនាករកម្រិតមធ្យម**

- ភាគរយនៃសំណង់ជំបូលដែលអនុលោមតាមយថាប្រភេទដែលបានព្រមព្រៀងជាមុន
- ចំនួនក្រុមការងារលំនៅដ្ឋានដែលទទួលការបណ្តុះបណ្តាល ដែលធ្វើប្រតិបត្តិការក្នុងភូមិគោលដៅ
- ភាគរយនៃការអង្កេតសហគមន៍ និងផែនការអនុវត្តន៍ជាក្រុម ដែលត្រូវបានបញ្ចប់

- ចំនួនក្រុមការងារលំនៅដ្ឋាន (KPs) ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងគោលការណ៍ណែនាំ
- ចំនួនឥណទានឥតសំណងដែលត្រូវបានបែងចែកសម្រាប់ការស្ថាបនាផ្ទះសម្បែងឡើងវិញ និងភាគរយនៃផ្ទះសម្បែងដែលប្រើប្រាស់ឈើស្របច្បាប់
- ភាគរយនៃផែនការតាំងទីលំនៅក្នុងសហគមន៍ (CSP) ដែលត្រូវបានរៀបចំឡើងដោយអនុលោមតាមគោលការណ៍ណែនាំ
- ភាគរយនៃសំណើហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានអនុម័ត
- ចំនួនគម្រោងត្រៀមខ្លួនឆ្លើយតបនឹងគ្រោះមហន្តរាយ ដែលត្រូវបានអនុវត្ត
- កម្រិតនៃការយល់ដឹងរបស់អ្នកទទួលផល (ទាំងពីរភេទ) ស្តីពីសិទ្ធិទទួលបាន និងដំណើរការគម្រោង
- ចំនួនក្រុមការងារលំនៅដ្ឋានដែលទទួលការបណ្តុះបណ្តាល ដែលត្រូវបានកៀរគរ
- ចំនួនកម្មវិធីបណ្តុះបណ្តាលការសាងសង់ ដែលត្រូវបានធ្វើឡើង
- ភាគរយនៃបណ្តឹងដែលត្រូវបានដោះស្រាយក្នុងរយៈពេល ៣ ខែ។

ឧទាហរណ៍ផ្សេងទៀតនៃយុទ្ធសាស្ត្រ និងក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព ដែលត្រូវបានអនុវត្តសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ រួមមាន ៖

- ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃថ្នាក់ជាតិរបស់អូស្ត្រាលីសម្រាប់កម្មវិធីស្តារឡើងវិញពីគ្រោះមហន្តរាយ (NEMA, 2018) ៖ ក្របខ័ណ្ឌនេះរៀបរាប់ពីដំណើរការជារួមដែលត្រូវបានបង្កើតឡើងសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ ជាមួយនឹងមូលដ្ឋានទិន្នន័យសូចនាករគ្រប់ជ្រុងជ្រោយ និងសកម្មភាពដែលអាចប្រើប្រាស់សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ អមជាមួយនឹងរបាយការណ៍ពិនិត្យតាមដាន និងវាយតម្លៃកន្លងមក ដើម្បីច្បាមយកចំណេះដឹង។ មូលដ្ឋានទិន្នន័យនេះត្រូវបានបង្កើតឡើងសម្រាប់ការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ តាមរយៈការផ្តល់ធាតុចូលជាហូរហែពីសំណាក់ភាគីពាក់ព័ន្ធ និងសហគមន៍។
- The Greater Christchurch Earthquake Recovery (CERA, 2012) រួមបញ្ចូលការពិនិត្យតាមដាន និងការរាយការណ៍ដែលផ្តល់គោលការណ៍រួមសម្រាប់សកម្មភាពពិនិត្យតាមដាន ដោយមានការរៀបចំរបាយការណ៍ពិនិត្យតាមដានជាក់លាក់ និងជាប្រចាំ ជុំវិញលទ្ធផលចុងក្រោយសំខាន់ៗ ដូចជា សន្ទស្សន៍សុខុមាលភាព Canterbury (Community & Public Health, n.d.)។
- សន្ទស្សន៍ New Orleans ត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ឆ្នាំ ចាប់តាំងពីមានព្រឹត្តិការណ៍ខ្យល់ព្យុះ Katrina។ អ្វីដែលសំខាន់គឺសហគមន៍បានចូលរួមយ៉ាងសកម្មក្នុងការបង្កើតសន្ទស្សន៍ តាមរយៈមជ្ឈមណ្ឌលទិន្នន័យ Greater New Orleans (Plyer, Shrinath, & Mack, 2015)។
- ប្រព័ន្ធជំនួយសង្គ្រោះ និងព័ត៌មានសម្រាប់គ្រោះរញ្ជួយដីនៅប៉ាគីស្ថាន (RISEPAK) ត្រូវបានបង្កើតឡើងក្រោយគ្រោះរញ្ជួយដីឆ្នាំ ២០០៥ នៅ Kashmir ដើម្បីផ្តល់ព័ត៌មានស្តីពីតម្រូវការ និងការឆ្លើយតបនៅថ្នាក់ភូមិ សម្រាប់ការវិភាគចំណុចខ្វះខាតក្នុងទិន្នន័យដែលប្រមូលដោយអ្នកចុះតាមមូលដ្ឋាន (RISE-PAK, 2006)។

- ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផលប៉ះពាល់នៃការស្តារឡើងវិញពីគ្រោះមហន្តរាយរលកយក្សស៊ូណាមិ (TRIAMS) ត្រូវបានអនុម័តដោយសម្ព័ន្ធសកលសម្រាប់បណ្តាប្រទេសដែលរងផលប៉ះពាល់ដោយសាររលកយក្សស៊ូណាមិ (ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាល់ឌីវ ស្រីលង្កា និងថៃ) ដើម្បីកំណត់ ផ្សព្វផ្សាយ និងគាំទ្រដល់ការតាមដានការស្តារឡើងវិញពីគ្រោះមហន្តរាយ ក្រោយព្រឹត្តិការណ៍រលកយក្សស៊ូណាមិក្នុងមហាសមុទ្រឥណ្ឌានៅឆ្នាំ ២០០៤។ TRIAMS បានបង្កើតសូចនាករលទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយ ដែលត្រូវបានបែងចែកជា ៤ កម្រិត ៖ តម្រូវការចាំបាច់ សេវាសង្គមមូលដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ និងរបរចិញ្ចឹមជីវិត (Dissanayake, 2018)។

ខាងក្រោមនេះជាសូចនាករមួយចំនួនដែលអាចយកទៅប្រើប្រាស់ក្នុងដំណើរការពិនិត្យតាមដាន និងវាយតម្លៃការស្តារវិស័យផ្លូវថ្នល់ឡើងវិញ ៖

- សូចនាករលទ្ធផលចុងក្រោយសំខាន់ៗ ៖
  - លទ្ធភាពទទួលបាន នៅចន្លោះតំបន់លំនៅដ្ឋានទាំងអស់ និងសេវាសំខាន់ៗ (មន្ទីរពេទ្យ ធនាគារ សាលារៀន កន្លែងស្ថាបនាផ្លូវ។ល។) ត្រូវបានស្តារឡើងវិញ។
  - សហគមន៍លើកឡើងពីការពេញចិត្តនឹងភាពងាយស្រួលក្នុងការធ្វើការងារ និងការទទួលបានសេវាសំខាន់ៗផ្សេងទៀត
  - % នៃផ្លូវដែលត្រូវបានចាក់ក្រាល មានការកើនឡើងតាំងពីមុនពេលគ្រោះមហន្តរាយ និង % នៃផ្លូវដែលមិនត្រូវបានចាក់ក្រាល និងផ្លូវដី មានការថយចុះ (បញ្ជាក់ពីការកសាងឡើងវិញឱ្យកាន់តែប្រសើរ)
  - ការថយចុះភាពងាយរងគ្រោះនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដោយសារទឹកជំនន់ (បញ្ជាក់ពីការកសាងឡើងវិញឱ្យកាន់តែប្រសើរជាមួយនឹងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយផលប៉ះពាល់)
- សូចនាករលទ្ធផលរំពឹងទុក
  - ភាគរយនៃផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវជនបទដែលត្រូវបានស្តារ ឬស្ថាបនាឡើងវិញ
  - ភាគរយនៃផ្លូវដែលត្រូវបានអ៊ិតកៅស៊ូ/បេតុង ផ្លូវដែលមិនត្រូវបានអ៊ិតកៅស៊ូ/បេតុង និងផ្លូវដី ក្រោយការស្តារឡើងវិញ
  - ភាគរយនៃស្ពានដែលត្រូវបានស្តារ ឬស្ថាបនាឡើងវិញ
  - ភាគរយនៃទ្រព្យសម្បត្តិផ្លូវថ្នល់ផ្សេងទៀតដែលត្រូវបានស្តារឡើងវិញ ឬជួសជុល
  - ភាគរយនៃផ្លូវដែលមានកម្ពស់ទាបជាងកម្រិតទឹកជំនន់ តាមការកំណត់ដោយការព្យាករណ៍ទឹកជំនន់ចុងក្រោយ (ការកំណត់រកហានិភ័យទឹកជំនន់)
  - ភាគរយនៃផ្លូវដែលមិនត្រូវបានអ៊ិតកៅស៊ូ/បេតុង និងស្ថិតក្រោមហានិភ័យទឹកជំនន់ (ការកំណត់ផ្លូវដែលងាយរងគ្រោះខ្លាំងដោយសារទឹកជំនន់)
- សូចនាករកម្រិតមធ្យម
  - ភាគរយនៃផែនការអង្កេតសហគមន៍ដែលបានបញ្ចប់
  - ភាគរយនៃគម្រោងដែលត្រូវបានដំណើរការតាមដំណាក់កាលជាបន្តបន្ទាប់ (ដំណើរការចុះកិច្ចសន្យា និងរចនា រហូតដល់លទ្ធកម្ម លទ្ធកម្មរហូតដល់ការសាងសង់។ល។)

- ចំនួនមន្ត្រីដែលទទួលការបណ្តុះបណ្តាលដែលចូលរួមក្នុងដំណើរការពិនិត្យតាមដាន និងវាយតម្លៃ
- ភាគរយនៃទ្រព្យសម្បត្តិផ្លូវថ្នល់ដែលត្រូវបានប៉ាន់ប្រមាណសម្រាប់ការវាយតម្លៃស្ថានភាព
- ភាគរយនៃបណ្តាញផ្លូវថ្នល់ដែលមានការវាយតម្លៃភាពងាយរងគ្រោះ។

# បង្កើតយុទ្ធសាស្ត្រទំនាក់ទំនង

ការបង្កើតឱ្យមានកិច្ចសន្ទនា និងទំនាក់ទំនងបន្តជាប់ រវាងរាល់ភាគីពាក់ព័ន្ធទាំងអស់ក្នុងដំណើរការស្តារវិស័យផ្លូវថ្នល់ឡើងវិញ ជាកត្តាសំខាន់ក្នុងការកសាងទំនុកចិត្ត និងគណនេយ្យភាពក្នុងដំណើរការនេះ ដើម្បីជានាការបន្សីគ្នានឹងចក្ខុវិស័យរួម និងគោលការណ៍ណែនាំ និងត្រូវបានធ្វើបច្ចុប្បន្នភាពទៅតាមការប្រែប្រួលតម្រូវការដែលកំណត់ដោយផ្នែកផ្សេងៗនៃប្រព័ន្ធនេះ។

យុទ្ធសាស្ត្រទំនាក់ទំនងផ្ទៃក្នុង និងជាសាធារណៈ ដែលមានភាពគ្រប់ជ្រុងជ្រោយ នឹងអាចកត់សម្គាល់ប្រភេទផ្សេងៗនៃភាគីពាក់ព័ន្ធ និងកំណត់មធ្យោបាយមានប្រសិទ្ធភាពបំផុតសម្រាប់ការធ្វើទំនាក់ទំនងជាមួយពួកគេ។

ដើម្បីបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងដែលមានប្រសិទ្ធភាព ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ គួរដឹកនាំការវាយតម្លៃរហ័សលើតម្រូវការទំនាក់ទំនង។ តារាងទី ២ បង្ហាញពីគំរូឯកសារសម្រាប់ការវាយតម្លៃតម្រូវការទំនាក់ទំនង។

**តារាងទី ២ ៖ គំរូឯកសារវាយតម្លៃតម្រូវការទំនាក់ទំនង**

| បញ្ហា | សំណួរដែលត្រូវសួរ |
|---|---|
| បរិបទស្ថានការណ៍ | តើអ្វីជាបរិបទនៃការសង្គ្រោះបន្ទាន់? <br> ▪ តើទ្រព្យសម្បត្តិផ្លូវថ្នល់ ត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ឬត្រូវបានបិទជាបណ្តោះអាសន្នដោយសារការរាំងស្ទះនេះ ឬទេ? <br> តើការស្តារឡើងវិញដំណើរការដូចម្តេច? <br> ▪ តើមានការដាក់ពង្រាយអង្គភាពសម្អាតផ្លូវថ្នល់ សម្រាប់ផ្លូវដែលត្រូវបានបិទជាបណ្តោះអាសន្ន ឬទេ? <br> ▪ តើមានការគ្រោងរៀបចំ ផ្សព្វផ្សាយ និងបង្ហាញពីផ្លូវវាងដល់សាធារណជន ខណៈដែលផ្លូវ និងស្ពានដែលរងការខូចខាត កំពុងត្រូវបានជួសជុល/ស្តារឡើងវិញ ឬទេ? <br> តើមានតួអង្គរដ្ឋាភិបាល និងតួអង្គមិនមែនរដ្ឋាភិបាលណាខ្លះដែលចូលរួមក្នុងការស្តារឡើងវិញ? <br> តើគ្រោះមហន្តរាយបង្កផលប៉ះពាល់លើលទ្ធភាពទទួលបានសេវាសំខាន់ៗ ឬទេ? <br> ▪ ប្រសិនបើប៉ះពាល់ តើការដាក់ពង្រាយសេវាសំខាន់ៗដល់សហគមន៍ ធ្វើឡើងដោយរបៀបណា? <br> ▪ តើមានការផ្សព្វផ្សាយពីផ្លូវជម្លៀសចេញ ជាមួយក្រុមឆ្លើយតបសង្គ្រោះបន្ទាន់ ដែលកំពុងផ្តល់សេវាសំខាន់ៗ ឬទេ? <br> តើមានអំពើហិង្សាដែលពាក់ព័ន្ធនឹងគ្រោះមហន្តរាយ ឬទេ? ឬ តើមានភាពផុយស្រួយស្រាប់ និងស្ថានភាពជម្លោះ ឬទេ? <br> ▪ តើសហគមន៍អាចទទួលបានសេវាផ្លូវច្បាប់ សម្រាប់ស្ថានភាពជម្លោះដែលអាចកើតឡើង ឬទេ? <br> តើរដ្ឋាភិបាលមានធនធានមនុស្ស និងធនធានហិរញ្ញវត្ថុអ្វីខ្លះ (ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន) សម្រាប់ជួយដល់ការអភិវឌ្ឍ និងការអនុវត្តផែនការទំនាក់ទំនង? |

| | |
|---|---|
| **ក្រុមគោលដៅ (អ្នកពាក់ព័ន្ធ)** | តើនរណាខ្លះជាក្រុមគោលដៅ (រួមបញ្ចូលអ្នកពាក់ព័ន្ធផ្សេងៗ)?<br>▪ តើសហគមន៍ណាខ្លះបាត់បង់លទ្ធភាពទទួលបាន ដោយសារការបិទផ្លូវ?<br>តើពួកគេមានតម្រូវការអ្វីខ្លះ?<br>តើមានបណ្តាញ និងដំណើរការផ្សព្វផ្សាយអ្វីខ្លះដែលអាចប្រើប្រាស់បាន?<br>តើមានបញ្ហាប្រឈម/ការរាំងស្ទះអ្វីខ្លះសម្រាប់ក្រុមគោលដៅ? តើមានរបាំងភូមិសាស្ត្រ វប្បធម៌ សេដ្ឋកិច្ចសង្គម និងរបាំងនយោបាយអ្វីខ្លះ ដែលរារាំងការជំរុញការចូលរួមរបស់ក្រុមគោលដៅ? |
| **គោលបំណង** | តើការផ្សព្វផ្សាយត្រូវសម្រេចលទ្ធផលអ្វីខ្លះ?<br>តើគួរផ្សព្វផ្សាយព័ត៌មានអ្វីខ្លះ?<br>▪ ប្លង់ផ្លូវវាង<br>▪ ចិរវេលានៃការជួសជុល និងការស្តារផ្លូវសំខាន់ៗ<br>▪ ព័ត៌មានបច្ចុប្បន្នភាពស្តីពីមធ្យោបាយធ្វើដំណើរសាធារណៈ |
| **មធ្យោបាយផ្សព្វផ្សាយ** | តើមធ្យោបាយផ្សព្វផ្សាយអ្វីខ្លះដែលសមស្របបំផុតសម្រាប់ក្រុមគោលដៅ?<br>តើត្រូវសម្រេចបានអ្វីខ្លះ? |
| **យោបល់ត្រឡប់** | តើគេអាចអនុវត្តយុទ្ធសាស្ត្រ ឬសកម្មភាពអ្វីខ្លះដើម្បីធានាការដាក់បញ្ចូលទស្សនៈយល់ឃើញ និងមតិយោបល់របស់សហគមន៍ (ទាំងវិជ្ជមាន និងអវិជ្ជមាន) ទៅក្នុងដំណើរការស្តារឡើងវិញ?<br>តើមានយន្តការដោះស្រាយបណ្តឹងជាស្រេចដែលអាចយកជាសំអាងបានដែរ ឬទេ? |

គោលការណ៍សំខាន់ៗនៃយុទ្ធសាស្ត្រទំនាក់ទំនងផ្ទៃក្នុងដែលមានប្រសិទ្ធភាព រួមមានការរួមចំណែកដល់តម្លាភាពនៃការស្តារឡើងវិញ ការកសាងភាពអាចជឿទុកចិត្តបាន និងការឯកភាពគ្នាលើគោលដៅនៃការស្តារឡើងវិញ និងការកំណត់តម្លាតវិសាលភាព និងចំណុចត្រួតគ្នាក្នុងគម្រោង។ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ គួរដឹកនាំការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងផ្ទៃក្នុង ដើម្បីផ្សព្វផ្សាយពី PDNA ក្នុងវិស័យផ្លូវថ្នល់។

គួរអនុវត្តជំហានខាងក្រោមដើម្បីគាំទ្រដល់ការធ្វើទំនាក់ទំនងជាមួយក្រុមស្តារឡើងវិញ និងម្ចាស់ជំនួយ៖

- ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទគួរកំណត់ពេលរៀបចំកិច្ចប្រជុំធ្វើសេចក្តីសម្រេចប្រចាំខែ ជាមួយដៃគូអន្តរជាតិ ដែលមានការផ្សព្វផ្សាយពីគោលបំណងនៃការស្តារឡើងវិញរបស់រដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល។ កិច្ចប្រជុំទាំងនេះនឹងផ្តល់ពេលវេលាដល់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល ដើម្បីឱ្យពួកគេអាចរក្សាការផ្តោតការយកចិត្តទុកដាក់លើការសម្រេចគោលបំណង និងបង្គោលចរនៃការស្តារឡើងវិញដែលបានកំណត់។
- សម្រាប់ទំនាក់ទំនងក្នុងក្រុមភាគីពាក់ព័ន្ធដែលចូលរួមដោយផ្ទាល់ក្នុងដំណើរការស្តារឡើងវិញ សូមបង្កើតគេហទំព័រចែករំលែកព័ត៌មានផ្ទៃក្នុង។ គេហទំព័រនេះគួរផ្តល់រាល់ព័ត៌មានទំនាក់ទំនង មូលដ្ឋានទិន្នន័យគ្រោះមហន្តរាយ និងខ្លឹមសារសង្ខេបកិច្ចពិភាក្សារវាងភាគីពាក់ព័ន្ធ។ គេក៏អាចប្រើប្រាស់គេហទំព័រនេះសម្រាប់សម្រួលដល់កិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយ (ដូចជា សិក្ខាសាលាអនឡាញ និងវេទិកាពិភាក្សា) បានផងដែរ។

ការពិភាក្សា និងការគូសប្លង់ជាមួយអ្នកធ្វើផែនការ អ្នកអនុវត្តន៍ និងក្រុមសហគមន៍ នឹងជួយពង្រឹងតម្លាភាព កាត់បន្ថយកិច្ចខិតខំប្រឹងប្រែងត្រួតគ្នា គូសបញ្ជាក់ពីគម្លាតក្នុងជំនួយ និងបង្កើតភាពឯកច្ឆ័ន្ទគ្នាលើការសម្រេចបានគោលដៅរួមនៃការស្តារឡើងវិញ។ ទំនាក់ទំនងផ្ទៃក្នុងនឹងផ្តល់ឱកាសសម្រាប់ការផ្លោះប្តូរយោបល់ត្រឡប់ក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់។ ទំនាក់ទំនងនេះក៏អាចដើរតួនាទីជាយន្តការសម្រាប់ការដោះស្រាយបណ្តឹងបានផងដែរ។

យុទ្ធសាស្ត្រផ្សព្វផ្សាយជាសាធារណៈប្រកបដោយប្រសិទ្ធភាព អាចកសាងការយល់ដឹងពីកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញក្នុងចំណោមសាធារណជន (ទាំងជាតិ និងអន្តរជាតិ) ជាពិសេសក្នុងប្រទេសម្ចាស់ជំនួយ។ យុទ្ធសាស្ត្រនេះគួរកំណត់ពីទំនាក់ទំនងសំខាន់ៗសម្រាប់ការផ្សព្វផ្សាយ អត្ថបទបោះពុម្ព និងបណ្តាញសង្គម។ សារទាំងនេះគឺដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការរំពឹងទុករបស់សាធារណជនចំពោះវិសាលភាព និងក្របខ័ណ្ឌពេលវេលានៃការស្តារឡើងវិញ។

ដើម្បីធានាការផ្សព្វផ្សាយជាសាធារណៈប្រកបដោយប្រសិទ្ធភាព គួរអនុវត្តសកម្មភាពដូចខាងក្រោម ៖

- កំណត់អត្តសញ្ញាណមន្ត្រីផ្សព្វផ្សាយព័ត៌មានសាធារណៈដែលនឹងរៀបចំពេលសម្ភាសន៍ ចេញសេចក្តីថ្លែងការណ៍ព័ត៌មាន និងប្រមូល និងផ្ទៀងផ្ទាត់ព័ត៌មាន
- ផ្តល់ព័ត៌មានពាក់ព័ន្ធដល់សាធារណជន ដើម្បីឱ្យពួកគេអាចការពារខ្លួន និងសហគមន៍បានប្រសើរជាងមុនពីផលប៉ះពាល់នៃគ្រោះមហន្តរាយ។ ព័ត៌មានរួមមាន ផ្លូវដែលមានស្រាប់ និងផ្លូវដែលនឹងមាននៅពេលដ៏ខ្លីខាងមុខ ផ្លូវវាង និងប្លង់សម្រាប់បណ្តាញដឹកជញ្ជូន។
- បង្កើតយន្តការផ្តល់យោបល់ត្រឡប់ដែលអាចឱ្យសាធារណជនចូលរួម កំណត់រកឱកាសថ្មីៗ លើកបញ្ហា ឬបណ្តឹង កំណត់រកអំពើពុករលួយ និងដាក់ស្នើជម្រើសសម្រាប់ការវិនិយោគ និងកម្មវិធីស្តាបនាបណ្តាញដឹកជញ្ជូនឡើងវិញ
- ប្រើប្រាស់មូលដ្ឋានទិន្នន័យរួម កិច្ចពិភាក្សាអនឡាញ និងតំណភ្ជាប់ផ្គាយរណបដើម្បីបង្កើនលំហូរព័ត៌មាន
- កំណត់រកវិធីចម្រុះសម្រាប់ការចែករំលែកព័ត៌មាន ដើម្បីឱ្យព័ត៌មានគ្របដណ្តប់លើប្រជាជនបានច្រើនបំផុត។ វិធីផ្សព្វផ្សាយ (GFDRR) រួមមាន ៖
  - កិច្ចប្រជុំសហគមន៍
  - សារព័ត៌មាន
  - វិទ្យុ
  - ក្តារប្រកាសដំណឹង
  - គេហទំព័រ
  - ទូរទស្សន៍
  - ទូរស័ព្ទចល័ត (សារខ្លីៗ/សារជាអត្ថបទ)
  - បណ្តាញសង្គម (Facebook, Twitter, Blogs...)
  - ការនិយាយពីមាត់មួយទៅមាត់មួយ

តាមរយៈការកត់សម្គាល់ពីសញ្ញានៃការស្តារឡើងវិញឆាប់រហ័ស និងការប្រកាសពីគោលដៅរយៈពេលវែង យុទ្ធសាស្ត្រផ្សព្វផ្សាយជាសាធារណៈប្រកបដោយប្រសិទ្ធភាព អាចឱ្យសហគមន៍ទាំងមូលដែលកំពុងស្តារឡើងវិញ និងសាធារណជនបានដឹងពីដំណាក់កាលបន្តបន្ទាប់នៃការស្តារ និងស្តាបនាឡើងវិញ។

# ការរៀនសូត្រយ៉ាងសកម្ម

តាមរយៈការអភិវឌ្ឍក្របខ័ណ្ឌស្តារឡើងវិញពីគ្រោះមហន្តរាយ ក្រោយពេលមានគ្រោះមហន្តរាយ និងការអនុវត្តក្របខ័ណ្ឌនេះសម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយ បទពិសោធន៍នេះនឹងនាំឱ្យភាគីពាក់ព័ន្ធទទួលបានការរៀនសូត្របន្ថែមទៀត។ សៀវភៅមគ្គុទេសក៍ស្តីពីការស្តារឡើងវិញពីគ្រោះមហន្តរាយ គួរមានការកែសម្រួលតាមដំណាក់កាល ដោយផ្អែកលើមេរៀនពីបទពិសោធន៍កន្លងមក ដូចជា ឃ្លាំងឯកសារស្តីពីការអនុវត្តដែលមានប្រសិទ្ធភាព និងការលុបចោលចំណុចណែនាំដែលលែងមានប្រសិទ្ធភាព ដោយសារការប្រែប្រួលប្រព័ន្ធស្ថាប័ននៃវិស័យផ្លូវថ្នល់នៅកម្ពុជា។

# គន្ថនិទ្ទេស


ADB. (2009). SECTOR ASSISTANCE PROGRAM EVALUATION ON TRANSPORT SECTOR IN CAMBODIA—FOCUSING ON RESULTS. ADB.

ADB. (2014). Disaster Risk Management in Cambodia. ADB.

ADB. (2019). Camobodia - Transport Sector Assessment, Strategy, and Road Map. ADB.

Banica, A., Kourtit, K., & Nijkamp, P. (2020). Natural disasters as a development opportunity: a spatial economic resilience interpretation. Review of Regional Research.

Behlert, B., Diekjobst, R., Felgentress, C., Manandhar, T., Mucke, P., Pries, L., . . . Weller, D. (2020). World Risk Report 2020. Ruhr University Bochum – Institute for International Law of Peace and Armed Conflict (IFHV).

CERA. (2012). Recovery Strategy for Greater Christchurch. CERA.

CFE-DM. (2020). Cambodia Disaster Management Reference Handbook. CFE-DM.

Community & Public Health. (n.d.). Canterbury Wellbeing Index. Retrieved from Canterbury Wellbeing Index: https://www.canterburywellbeing.org.nz/

Dissanayake, L. (2018). Tsunami Recovery Impact Assessment and Monitoring System (TRIAMS): Methodological Approach for Recovery . In The Asian Tsunami and Post-Disaster Aid.

Euklidiadas, M. (2021). SMART TUNNEL: WHAT IS IT, HOW DOES IT WORK AND THE REAL EXAMPLE OF MALAYSIA. Retrieved from Tomorrow City: https://tomorrow.city/a/smart-tunnel

FHWA. (2013). EMERGENCY RELIEF MANUAL (Federal-Aid Highways) . FHWA.

FHWA. (2018). FHWA Vulnerability Assessment and Adaptation Framework.

GFDRR. (2018). Methdology Note on the Global Rapid Post-Disaster Damage Estimation (GRADE) Approach. GFDRR.

GFDRR. (2018). Transport Sector Recovery: Opportunities to Build Resilience .

GFDRR. (2020). Disaster Recovery Framework Guide. Revised Version. GFDRR.

GFDRR. (n.d.). Communication during Disaster Recovery. 2019: GFDRR.

Hess, W., Pang, J., & Nelson, B. (2016). Construction of the World's Longest Floating Bridge. Retrieved from Structure: https://www.structuremag.org/?p=10525

IFAI Industry News. (2022). Resilient Roads Roundtable announces innovators/influencers list. Retrieved from Georsynthetics ATA Publication: https://geosyntheticsmagazine.com/2022/03/15/resilient-roads-roundtable-announces-innovators-influencers-list/

JICA. (2006). THE STUDY ON THE ROAD NETWORK DEVELOPMENT IN THE KINGDOM OF CAMBODIA .

JICA. (2014). Preparatory Survey for National Road No.5 Improvement Project (Middle Section: Thlea Ma'am – Battambang, and Sri Sophorn – Poipet). JICA.

Katich, K. (n.d.). Monitoring and evaluation in disaster risk management. EAP DRM KnowledgeNotes.

KCI. (2011). TA No 7665-CAM Preparing the Provincial Roads Improvement Project . ADB.

KCI. (n.d.). TA No 7665-CAM Preparing the Provincial Roads Improvement Project . 2011: ADB.

Kingdom of Cambodia. (2015). Law on Disaster Management. Kingdom of Cambodia.

MPWT. (2001). Ministry of Public Works and Transport. Retrieved from PRAKAS NO. 177 DATED 11 OCTOBER, 2001- STANDARDS FOR PUBLIC CONSTRUCTION REGARDING DETERMINATION OF OFFICIAL USE OF TECHNICAL STANDARDS, BRIDGES AND ROADS (CONSTRUCTION SPECIFICATION): https://www.mpwt.gov.kh/en/documents/declaration/57

MRD. (2014). CAM: Rural Roads Improvement Project II . ADB.

NEMA. (2018). National monitoring and evaluation for disaster recovery programs. Australian Government | NEMA.

OpenDevelopment Cambodia. (2015). Infrastructure. Retrieved from OpenDevelopment Cambodia: https://opendevelopmentcambodia.net/topics/infrastructure/

Partnerships for Infrastructure. (2022). Australian Government - Partnerships for Infrastructure . Retrieved from Austroads assists Cambodia with road design standards update: https://www.partnershipsforinfrastructure.org/newsroom/austroads-assists-cambodia-road-design-standards-update

Plyer, A., Shrinath, N., & Mack, V. (2015). The New Orleans Index at Ten Measuring Greater New Orleans' Progress toward Prosperity.

RISE-PAK. (2006). Relief and Information Systems for Earthquakes Pakistan . Retrieved from https://web.archive.org/web/20051023004933/http://www.risepak.com/

Royal Government of Cambodia. (2010). Cambodia Post-Ketsana Disaster Needs Assessment . GFDRR.

Savani, K. (2016). Design of Temporary Deployable bridge to Rehabilitate Traffic after Disaster.

Siev, S., Ann, V., Nakamura, T., Fujii, H., & Yoshimura, C. (2020). Flood mapping under an extreme event in a large shallow lake influenced by flood pulse in Southeast Asia. E3S Web of Conferences.

Singh, P. (2022). PDNA Guidelines: Roadways Sector in Cambodia (Draft).

Singh, P., Amekudzi-Kennedy, A., Woodall, B., & Joshi, S. (2021). Lessons from case studies of flood resilience: Institutions and built systems. Transportation Research Interdisciplinary Perspectives.

The World Bank. (2015). Disaster Risk Financing and Insurance (DRFI) Program . Retrieved from The World Bank: https://www.worldbank.org/en/programs/disaster-risk-financing-and-insurance-program

UNDP. (2022). Disaster Financial Preparedness Analysis Report (Draft). UNDP.

UNDP. (2022). Water Supply, Sanitation and Hygiene (WASH) Disaster Recovery Framework Guide. UNDP.

World Bank. (2016). Thematic discussion — 1 : Sustainable transport at the heart of the Sustainable Development Goals. Global Sustainable Transport Conference.

**United Nations Development Programme (UNDP)**
No. 53, Pasteur Street, Boeung Keng Kang I,
PO Box 877 Phnom Penh, Cambodia